# អង្គការសហប្រជាជាតិ
# ក្រុមប្រឹក្សាសិទ្ធិមនុស្ស

## អនុសាសន៍ស្តីពីការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់

## ស្តីពី

## ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

(សំរាប់ជុំទី២)

UNITED NATIONS

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ខែវិច្ឆិកា ឆ្នាំ២០១៤

# អង្គការសហប្រជាជាតិ

# ក្រុមប្រឹក្សាសិទ្ធិមនុស្ស

## អនុសាសន៍ស្តីពីការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់

# ស្តីពី

# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

*(សំរាប់ជុំទី២)*

# អារម្ភកថា

យន្តការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺជាដំណើរការតែមួយគត់ អំពីកំណត់ត្រាសិទ្ធិមនុស្សរបស់សមាជិកនីមួយៗទាំង១៩៣ប្រទេស នៃអង្គការសហប្រជាជាតិ។ ដោយមានគោលដៅខ្ពស់បំផុត ក្នុងការធ្វើឲ្យកាន់តែប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅគ្រប់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ UPR ត្រូវបានបង្កើតឡើង ដើម្បីបង្កើន គាំទ្រ និងពង្រីកការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗ។ UPR គឺជាដំណើរការខិតខំប្រឹងប្រែងរបស់រដ្ឋ ដែលផ្តល់ឱកាសដល់រដ្ឋនីមួយៗ ប្រកាសពីការចាត់វិធានការនានា ដើម្បីធ្វើឲ្យប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស និងបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន នៅចំពោះមុខរដ្ឋដទៃទៀត និងចំពោះសាធារណៈជនទូទៅ។ UPR បង្កើតឱកាសផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋនានា និងលើកកំពស់សមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាប្រឈមសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព និងចែករំលែកការអនុវត្តន៍ល្អៗ នៅក្នុងវិស័យសិទ្ធិមនុស្សរវាងរដ្ឋនានា និងដៃគូដទៃទៀត។ ជាទិដ្ឋភាពចំបងមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស UPR ត្រូវបានបង្កើតឡើង ដើម្បីធានាឲ្យមានការពិនិត្យដោយស្មើភាពគ្នាដល់រដ្ឋទាំងអស់ នៅពេលស្ថានភាពសិទ្ធិមនុស្សរបស់ពួកគេត្រូវបានយកមកវាយតំលៃម្តងៗ។ គ្រប់រដ្ឋត្រូវស្ថិតនៅក្រោមដំណើរការដូចគ្នា និងការត្រួតពិនិត្យដូចគ្នា ដោយមិនគិតពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនោះទេ។ សព្វថ្ងៃនេះ មិនមានយន្តការសកលដទៃណា របៀបនេះនោះទេ។

កម្ពុជា ត្រូវបានពិនិត្យដំបូង ក្រោមដំណើរការ UPR កាលពីខែធ្នូ ឆ្នាំ២០០៩។ នៅចុងបញ្ចប់នៃការពិនិត្យលើកដំបូងរបស់ខ្លួន កម្ពុជាបានទទួលយកទាំង៩១អនុសាសន៍ ដែលធ្វើឡើងដោយរដ្ឋនានា។[១] ជុំដំបូងនៃដំណើរការ UPR បានចប់សព្វគ្រប់កាលពីខែតុលា ឆ្នាំ២០១១ នៅពេលដែលរដ្ឋសមាជិកទាំងអស់១៩៣ របស់អង្គការសហប្រជាជាតិ ត្រូវបានពិនិត្យ។ បន្ទាប់មកជុំទីពីរបានចាប់ផ្តើម ហើយកម្ពុជាត្រូវបានពិនិត្យជាថ្មីម្តងទៀត កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤។ គ្រប់ទិន្នន័យព័ត៌មាន ត្រូវបានដាក់ចូលសំរាប់ការត្រួតពិនិត្យលើកទី២នេះ រួមមានរបាយការណ៍ជាតិរបស់រាជរដ្ឋាភិបាល និងកម្រងព័ត៌មានពីយន្តការសិទ្ធិមនុស្សសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ហើយព័ត៌មានទាំងនេះ សុទ្ធតែអាចរកបាននៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[២] កិច្ចសន្ទនានៃការត្រួតពិនិត្យនេះ ក៏អាចរកមើលផងដែរនៅក្នុងគេហទំព័រនេះ។[៣]

*១. អនុសាសន៍ទាំងនេះ អាចរកបាននៅគេហទំព័រៈ* http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession6.aspx

*២. ឯកសារទាំងនេះអាចរកបាននៅគេហទំព័រ* http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession18.aspx. *ដើម្បីរកមើលការដាក់ឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រជាជាតិនីមួយៗ សូមចុចលើរឹមទំព័រនៃគេហទំព័រនោះ។*

*៣. សូមមើលគេហទំព័រៈ* http://webtv.un.org/watch/cambodia-review-18th-session-of-universal-periodic-view/3119784522001/

ក្នុងកំឡុងពេលពិនិត្យចុងក្រោយនេះ មានអនុសាសន៍ចំនួន២០៥ បានដាក់ជូនកម្ពុជា ដែលត្រូវយកមកបោះពុម្ពផ្សាយនៅក្នុងសៀវភៅនេះ។ ក្នុងខែមករា កម្ពុជាបានទទួលអនុសាសន៍ចំនួន ១៧១ ហើយបានសុំពន្យាពេលធ្វើសេចក្តីសំរេចលើអនុសាសន៍ដែលនៅសល់ចំនួន៣៤ រហូតដល់សម័យប្រជុំខែមិថុនា របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ កម្ពុជាបានប្រកាសពីជំហរចុងក្រោយរបស់ខ្លួនថា ខ្លួនព្រមទទួលយកតែ១៦២ អនុសាសន៍ប៉ុណ្ណោះ និងសូមធ្វើការកត់សំគាល់ចំពោះអនុសាសន៍ចំនួន៤២ទៀត។ អនុសាសន៍ UPR បង្ហាញនូវការវាយតំលៃជារួមមួយអំពីតថភាពនៃកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងចំណុចឆកល្វែង និងឱកាសពាក់ព័ន្ធនានា ដើម្បីពង្រឹងដល់កិច្ចការពារនេះ។

ដើម្បីបង្ហាញពីការរីកចំរើននៅជុំបន្ទាប់នៃUPR ដែលនឹងត្រូវប្រព្រឹត្តទៅក្នុងរវាង៤ឆ្នាំទៀត រដ្ឋាភិបាល នឹងត្រូវចាត់វិធានការជាក់ស្តែងភ្លាមៗ ឆ្ពោះទៅរកការអនុវត្តន៍អនុសាសន៍ទាំងនេះ។ ការអនុវត្តន៍ដ៏មានអត្ថន័យ និងមានការឯកភាពគ្នា នៃអនុសាសន៍UPR ត្រូវធានាថា រាល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ព្រមទាំងដៃគូចូលរួមដទៃទៀត នឹងឆ្ពោះទៅរកការរីកចំរើនដ៏មានអត្ថន័យ។ កិច្ចខិតខំប្រឹងប្រែងបែបនេះ នឹងរួមចំណែកដល់ការអនុវត្តន៍អនុសាសន៍នានា ដែលបានដាក់ចេញកាលពីមុនៗ ដោយស្ថាប័នសន្ធិសញ្ញា និងយន្តការសិទ្ធិមនុស្សដទៃទៀត ដូចជាអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាជាដើម ដែលអនុសាសន៍ទាំងនោះភាគច្រើន មានឆ្លុះបញ្ចាំងនៅក្នុងអនុសាសន៍ UPR ។ ការអនុវត្តន៍ដ៏ជោគជ័យ នឹងជួយដល់ការព្រាងរបាយការណ៍បន្ទាប់របស់ UPR កាន់តែមានភាពងាយស្រួល។

ដើម្បីសំរេចបានគោលបំណងនេះ ជាសំខាន់រដ្ឋត្រូវកំណត់ពីស្ថាប័នជាក់លាក់នានារបស់ខ្លួន ដើម្បីទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍តាមវិស័យជាក់លាក់រៀងៗខ្លួន។ កិច្ចការត្រូវចាប់ផ្តើមភ្លាមៗ ដើម្បីកំណត់ ក)បញ្ហានានាដែលពាក់ព័ន្ធ ខ)អាជ្ញាធរទទួលខុសត្រូវ និងគ)ការចាត់វិធានការជាក់លាក់ដើម្បីអនុវត្តអនុសាសន៍។ ជាសំខាន់ត្រូវរំលឹកថា ការទទួលខុសត្រូវក្នុងការចាត់វិធានការ មិនមែនអាស្រ័យទាំងស្រុងលើអំណាចនីតិប្រតិបត្តិនោះទេ។ មានអនុសាសន៍ខ្លះតម្រូវឲ្យមានការអនុម័ត ឬការកែសម្រួលច្បាប់ ជាឧទាហរណ៍ គឺសភា នឹងត្រូវដើរតួនាទីយ៉ាងសំខាន់នេះ។

ទិដ្ឋភាពតែមួយគត់នៃដំណើរការUPR គឺថា វាឆ្លុះបញ្ចាំងនូវការប្រមូលផ្តុំនៃទស្សនៈអន្តរជាតិអំពីស្ថានភាពសិទ្ធិមនុស្ស នៅតាមប្រទេសនីមួយៗដែលស្ថិតក្រោមការពិនិត្យ ហើយអនុសាសន៍ដែលជាលទ្ធផលពីការពិនិត្យនេះ ត្រូវបានទទួលយកដោយស្ម័គ្រចិត្ត និងជាសាធារណៈដោយរដ្ឋ

ដែលស្ថិតក្រោមការពិនិត្យ។ ដូច្នេះ អនុសាសន៍ទាំងនេះ អាចក្លាយជាឧបករណ៍នៃការតស៊ូមតិដ៏មានអំណាចបំផុត សំរាប់ដៃគូពាក់ព័ន្ធទាំងអស់។ អនុសាសន៍នីមួយៗ គួរបរិយាយនៅក្នុងផែនការជាក់ស្តែង ដើម្បីអនុវត្ត ឬគាំទ្រការអនុវត្តន៍អនុសាសន៍ UPR។ ការទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍ UPR ជាការពិតហើយ ជារបស់រដ្ឋាភិបាល ក៏ប៉ុន្តែសង្គមស៊ីវិល ក៏អាច និងគួរដើរតួសំខាន់ក្នុងការជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៅក្នុងវិស័យនេះដែរ។ សង្គមស៊ីវិល ក៏ដើរតួនាទីសំខាន់ផងដែរ ក្នុងការតាមឃ្លាំមើលស្ថានភាពនៃការអនុវត្តន៍អនុសាសន៍ទាំងនេះ។

រួមជាមួយអនុសាសន៍នានារបស់យន្តការជំនាញ ដូចជាគណៈកម្មាធិការឃ្លាំមើលសន្ធិសញ្ញា និងអ្នករាយការណ៍ពិសេសនានា អនុសាសន៍ UPR ថ្លែងពីបញ្ហានានា ដែលមានលក្ខណៈទូលំទូលាយ គ្របដណ្តប់លើវិស័យនានា ដែលក្នុងនោះ ទីភ្នាក់ងារសហប្រជាជាតិ ជារឿយៗតែងផ្តល់ការគាំទ្រដល់រដ្ឋាភិបាល។ ក្នុងករណីនេះ ដោយទទួលយកការណែនាំពីអនុសាសន៍ទាំងនេះ ទីភ្នាក់ងារសហប្រជាជាតិ អាចផ្តល់ជំនួយដ៏មានសារៈសំខាន់ ដល់ការអនុវត្តន៍ UPR នៅក្នុងវិស័យជាក់លាក់ដែលខ្លួនមានសមត្ថកិច្ច។

អនុសាសន៍ពីគ្រប់យន្តការសិទ្ធិមនុស្សអាចប្រើជាកាតាលីករ—ហើយធ្លាប់បានអនុវត្តបែបនេះនៅតាមបណ្តាប្រទេសជាច្រើន—សំរាប់រដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍អន្តរជាតិ និងប្រព័ន្ធសហប្រជាជាតិ ចូលរួមប្រឹងប្រែងក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ដើម្បីធ្វើឲ្យកិច្ចការពារសិទ្ធិមនុស្សកាន់តែប្រសើរ។ ឱកាសអនុវត្តដូចគ្នាបែបនេះនៅកម្ពុជា មិនគួរត្រូវបានបោះបង់ឡើយ។ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូជាច្រើន ដែលបានយកចិត្តយ៉ាងជ្រាលជ្រៅ ដល់ការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ត្រៀមខ្លួនជាស្រេចដើម្បីចូលរួមក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ជាមួយពួកគេ ដោយឆ្លៀតយកប្រយោជន៍ពីការបើកជាថ្មីដល់កំណែទម្រង់ដ៏ទាន់ពេល ដើម្បីចាប់ផ្តើមដំណើរការអនុវត្ត UPR នេះ ដោយម៉ឺងម៉ាត់។ ការិយាល័យឧត្តមស្នងការ បានជួយដល់ការបោះពុម្ពនេះ ថាជាជំហានដំបូងនៅក្នុងទិសដៅនេះ។ នេះគឺជាការឧទ្ទិសដល់ប្រជាជនកម្ពុជា និងអ្នកទាំងឡាយណាដែលចូលរួមការពារសិទ្ធិមនុស្សរបស់ពួកគេ។

*លោកស្រី វ៉ាន់ហ៊ី លី*

*តំណាង*

*ការិយាល័យ* OHCHR-Cambodia

ខែវិច្ឆិកា ឆ្នាំ២០១៤

# អំពីដំណើរការ UPR

ការត្រួតពិនិត្យ ត្រូវបានធ្វើឡើងរៀងរាល់៤.៥ ឆ្នាំម្តង ដោយក្រុមការងារ UPR ដែលមានសមាជិកចំនួន៤៧រដ្ឋ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ទោះបីជារដ្ឋសមាជិកណាមួយរបស់អង្គការសហប្រជាជាតិ អាចចូលរួមក្នុងកិច្ចពិភាក្សា/សន្ទនា ជាមួយរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យក៏ដោយ។ រដ្ឋនីមួយៗដែលស្ថិតក្រោមការពិនិត្យ ត្រូវបានជួយដោយក្រុមនៃរដ្ឋបី ដែលដឹងថាជា "troikas" ធ្វើជាអ្នករាយការណ៍។ ការជ្រើសរើស troikas សំរាប់រដ្ឋនីមួយៗ ត្រូវធ្វើតាមរយៈការចាប់ឆ្នោត បន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។

ការត្រួតពិនិត្យនេះ ផ្អែកលើឯកសារបី៖

១. ព័ត៌មានដែលផ្តល់ឲ្យដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យ ដែលអាចធ្វើតាមទម្រង់ជា "របាយការណ៍ជាតិ"។

២. ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញការ និងក្រុមឯករាជ្យខាងសិទ្ធិមនុស្ស រួមមាននីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងស្ថាប័នសហប្រជាជាតិដទៃទៀត។

៣. ព័ត៌មានពីដៃគូដទៃទៀតរួមមានស្ថាប័នសិទ្ធិមនុស្សជាតិនិងអង្គការមិនមែនរដ្ឋាភិបាល។

UPR នឹងវាយតំលៃពីវិសាលភាពដែលរដ្ឋគោរពកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនដូចមានចែងក្នុង (១)ធម្មនុញ្ញសហប្រជាជាតិ (២)សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (៣)លិខិតុបករណ៍សិទ្ធិមនុស្សដែលរដ្ឋនោះជាភាគី (សន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលរដ្ឋនោះបានផ្តល់សច្ចាប័ន) (៤) ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តធ្វើដោយរដ្ឋនោះចំពោះសហគមន៍អន្តរជាតិ (ឧ. គោលនយោបាយសិទ្ធិមនុស្សជាតិ និង/ឬកម្មវិធីនានាដែលត្រូវអនុវត្ត) និង(៥)ច្បាប់មនុស្សធម៌អន្តរជាតិដែលនៅជាធរមាន។

ការត្រួតពិនិត្យ ប្រព្រឹត្តទៅតាមរយៈកិច្ចសន្ទនាគ្នាជាអន្តរកម្មរវាងរដ្ឋស្ថិតនៅក្រោមការពិនិត្យ និងសមាជិកដទៃទៀតរបស់សហប្រជាជាតិ។ កិច្ចនេះប្រព្រឹត្តទៅក្នុងកំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារ UPR។ ក្នុងកំឡុងពេលពិភាក្សាគ្នានេះ សមាជិកណាក៏ដោយរបស់អង្គការសហប្រជាជាតិ អាចតាំងសំណួរ យោបល់ និង/ឬធ្វើអនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ។ រយៈពេលនៃការត្រួតពិនិត្យ គឺ៣ម៉ោង និង៣០នាទី។

បន្ទាប់ពីការត្រួតពិនិត្យដោយក្រុមការងារ troika នឹងរៀបចំរបាយការណ៍មួយ ដោយមានការចូលរួមពីរដ្ឋដែលស្ថិតក្រោមការពិនិត្យ និងជំនួយពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ របាយការណ៍នេះដែលត្រូវទុកជា "របាយការណ៍លទ្ធផល" រៀបរាប់យ៉ាងសង្ខេបពីកិច្ចសន្ទនាគ្នានោះ។ ដូច្នេះ របាយការណ៍នេះ មានសំណួរ យោបល់ និងអនុសាសន៍ដែលដាក់ដោយរដ្ឋនានាដល់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ព្រមទាំងការឆ្លើយតបរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ។

ពេលវេលាត្រូវបានផ្តល់ឲ្យក្រុមការងារដើម្បីអនុម័ត "របាយការណ៍លទ្ធផល" នីមួយៗរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ក្នុងកំឡុងសម័យប្រជុំនោះ។ រដ្ឋដែលស្ថិតក្រោមការពិនិត្យ មានឱកាសផ្តល់យោបល់បឋម ទៅលើអនុសាសន៍នានា ជ្រើសរើសថាព្រមទទួលយក ឬគ្រាន់តែធ្វើការកត់សំគាល់លើអនុសាសន៍ទាំងនោះ។ ទាំងអនុសាសន៍ដែលបានទទួលយក និងអនុសាសន៍ដែលគ្រាន់តែធ្វើការកត់សំគាល់ ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ។

បន្ទាប់មក របាយការណ៍នេះ ត្រូវដាក់ជូនសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីទទួលការអនុម័ត។ នៅពេលនោះ រដ្ឋដែលស្ថិតក្រោមការពិនិត្យអាចឆ្លើយទៅនឹងសំណួរ និងបញ្ហានានាដែលមិនទាន់បានឆ្លើយគ្រប់គ្រាន់នៅកំឡុងពេលក្រុមការងារ និងឆ្លើយតបចំពោះអនុសាសន៍ដែលត្រូវបានលើកឡើងដោយរដ្ឋនានាក្នុងកំឡុងពេលនៃការត្រួតពិនិត្យ។ ពេលវេលាក៏មានផ្តល់ជូនរដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍ដែរ ដែលចង់សំដែងមតិរបស់ខ្លួន អំពីលទ្ធផលនៃការត្រួតពិនិត្យនេះ និងក៏មានផ្តល់ជូនស្ថាប័នសិទ្ធិមនុស្សជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីផ្តល់យោបល់ជាទូទៅដែរ។

រដ្ឋដែលស្ថិតក្រោមការពិនិត្យ តែងតែមានការទទួលខុសត្រូវបឋម ដើម្បីអនុវត្តអនុសាសន៍នានាដែលមាននៅក្នុងរបាយការណ៍លទ្ធផលចុងក្រោយ។ UPR ធានាថា គ្រប់ប្រទេស ត្រូវទទួលខុសត្រូវចំពោះការរីកចំរើន ឬការខកខានក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ ក្នុងកំឡុងការត្រួតពិនិត្យលើកក្រោយ រដ្ឋត្រូវបានរំពឹងថា នឹងផ្តល់ព័ត៌មានអំពីវិធានការនានាដែលខ្លួនបានចាត់ឡើងដើម្បីអនុវត្តអនុសាសន៍នានាដែលបានផ្តល់ឲ្យកាលពីលើកមុន ព្រមទាំងអំពីការវិវត្តន៍ណាមួយនៅក្នុងវិស័យសិទ្ធិមនុស្ស។ សហគមន៍អន្តរជាតិ មានតួនាទីជួយអនុវត្តអនុសាសន៍ទាំងនេះ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ដោយពិគ្រោះយោបល់ជាមួយរដ្ឋសាមី។

☜☜☜@☞☞☞

# របាយការណ៍របស់ក្រុមការងារអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់

(A/HRC/26/16, 27 March 2014)

# កម្ពុជា

## សេចក្តីផ្តើម

1. ក្រុមការងារអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) ដែលត្រូវបានបង្កើតឡើង ស្របតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ បានបើកសម័យប្រជុំលើកទី១៨ របស់ខ្លួន ពីថ្ងៃទី២៧ ខែមករា ដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤។ ការពិនិត្យឡើងវិញនៃប្រទេសកម្ពុជា ត្រូវបានធ្វើឡើងនៅឯកិច្ចប្រជុំទី៤ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤។ គណៈប្រតិភូកម្ពុជាដឹកនាំដោយ ឯ.ឧ.ម៉ក់ សម្បត្តិ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ នៅឯកិច្ចប្រជុំលើកទី១០របស់ខ្លួនដែលបានធ្វើឡើងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ក្រុមការងារនេះបានអនុម័តរបាយការណ៍អំពីកម្ពុជា។

2. នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានជ្រើសរើសក្រុមអ្នករាយការណ៍ (ក្រុមបីប្រទេស) ដូចខាងក្រោម ដើម្បីសម្របសម្រួលដល់ការពិនិត្យឡើងវិញលើប្រទេសកម្ពុជា៖ ប្រទេសអ៊ីតាលី ម៉ូរ៉ុកកូ និងហ្វីលីពីន។

3. ស្របតាមវាក្យខណ្ឌទី១៥ នៃឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសំរេចលេខ៥/១ និងវាក្យខណ្ឌទី៥ នៃឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសម្រេចលេខ១៦/២១ ឯកសារទាំងឡាយដូចខាងក្រោមនេះ ត្រូវបានចេញ សម្រាប់ការពិនិត្យឡើងវិញនៃប្រទេសកម្ពុជា៖

(a) របាយការណ៍ជាតិមួយ ដែលត្រូវបានបញ្ជូនមក/បង្ហាញមក ជាលាយលក្ខណ៍អក្សរ ស្របតាមវាក្យខណ្ឌទី១៥(a) (A/HRC/WG.6/18/KHM/1);

(b) កម្រងឯកសារមួយ ដែលចងក្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមវាក្យខណ្ឌទី១៥(b) (A/HRC/WG.6/18/KHM/2);

(c) សេចក្តីសង្ខេបមួយ ដែលរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមវាក្យខណ្ឌទី១៥(c) (A/HRC/WG.6/18/KHM/3)

4. បញ្ជីសំណួរមួយដែលបានរៀបចំរួចជាមុន ដោយប្រទេសបែលហ្ស៊ិក សាធារណរដ្ឋឆែក អាល្លឺម៉ង់ ស្លូវេនី ម៉ិកស៊ិកូ លីឆតេនស្ទេន ហូឡង់ដ៍ ស៊ុយអែត ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ត្រូវបានបញ្ជូនមកកម្ពុជា តាមរយៈក្រុមបីប្រទេស(troika)។ សំណួរទាំងនេះ មាននៅគេហទំព័ររបស់ UPR។

# I. សង្ខេបនីតិវិធីនៃដំណើរការពិនិត្យឡើងវិញ

## ក. បទបង្ហាញដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

5. គណៈប្រតភូកម្ពុជា បានបញ្ជាក់ពីសារៈសំខាន់នៃយន្តការ UPR ថាជាដំណើរការមួយ ដែលផ្តល់ឱកាសដល់រដ្ឋនីមួយៗ ឲ្យអនុវត្តវិធានការនានា ដើម្បីកែលម្អស្ថានភាពសិទ្ធិមនុស្ស នៅក្នុងទឹកដីរបស់ខ្លួន។

6. គណៈប្រតិភូបានរំលឹកថា ការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា ត្រូវបានពិនិត្យដោយក្រុមការងារ UPR កាលពីខែធ្នូ ឆ្នាំ២០០៩ម្តង ហើយថាអនុសាសន៍ទាំង៩១ចំណុចដែលបានតាក់តែងឡើងនាពេលនោះ គឺស្របគ្នានឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

7. គណៈប្រតិភូបានពន្យល់ថា បន្ទាប់ពីបានទទួលអនុសាសន៍ទាំង៩១ចំណុចមក អាជ្ញាធរកម្ពុជាបានតែងតាំងក្រុមការងារមួយដែលដឹកនាំដោយ ឯកឧត្តម ម៉ក់ សម្បត្តិ និងមានសមាជិកចំនួន ២១រូប មកពីក្រសួង និងស្ថាប័នពាក់ព័ន្ធនានា។ ក្រុមការងារនេះបានសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស រៀបចំសិក្ខាសាលាចំនួនពីរ ដោយមានការចូលរួមពីអ្នកជំនាញ មកពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងហ្វីលីពីន។ ក្រុមការងារនេះ ក៏បានរៀបចំកិច្ចប្រជុំចំនួនប្រាំផងដែរជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា និងកិច្ចពិគ្រោះយោបល់ចំនួនពីរជាមួយអង្គការសង្គមស៊ីវិល។ នៅក្នុងខែតុលា ឆ្នាំ២០១៣ គណៈរដ្ឋមន្ត្រី ក្រោមការគាំទ្រពីនាយករដ្ឋមន្ត្រី បានអនុម័តរបាយការណ៍នេះ។

8. គណៈប្រតិភូបានកត់សម្គាល់ពីសមិទ្ធផលវិជ្ជមាន បញ្ហាប្រឈម និងគោលដៅអនាគតនៅក្នុងវិស័យធំៗ ចំនួនប្រាំពីរ៖ (១)ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា (២)សិទ្ធិដីធ្លី (៣)នីតិរដ្ឋ (៤)ការឃុំខ្លួន និងបញ្ហានានាទាក់ទងនឹងទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី (៥)សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (៦)សិទ្ធិស្ត្រី និង (៧)សិទ្ធិកុមារ។

9. គណៈប្រតិភូបានបញ្ជាក់ថា កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ចំនួន៩។ ទាក់ទងទៅនឹងពិធីសារបន្ថែមចំនួនពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដោយមានជំនួយពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានរៀបចំសិក្ខាសាលា និងកិច្ចប្រជុំចំនួនពីរលើកជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា។

10. ទាក់ទងទៅនឹងការអញ្ជើញ *អ្នកកាន់អាណត្តិនៃនីតិវិធីពិសេស* គណៈប្រតិភូបានបញ្ជាក់ថា មិនចាំបាច់អញ្ជើញពួកគាត់នោះទេ ដោយសារថា ពួកគាត់អាចមកទស្សនកិច្ចកម្ពុជា នៅពេលណាក៏បាន។ គណៈប្រតិភូបានបង្ហាញថា បច្ចុប្បន្ននេះមានអង្គការជាច្រើន ដែលធ្វើការលើបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេស រួមមាន គណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងរដ្ឋសភា គណៈកម្មការសិទ្ធិមនុស្សនិងទទួលពាក្យបណ្តឹងព្រឹទ្ធសភា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អង្គការជាតិ និងអន្តរជាតិរាប់រយអង្គការ រួមទាំង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាផង។

11. ទាក់ទងទៅនឹងបញ្ហាដីធ្លី គណៈប្រតិភូបានកត់សម្គាល់ថា អាជ្ញាធរកម្ពុជាបន្តចុះបញ្ជីដីគ្រប់ប្រភេទ ក្នុងគោលបំណងពង្រឹងសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី។ យុទ្ធនាការអនុវត្ត "គោលនយោបាយចាស់ សកម្មភាពថ្មី"ក្នុងវិស័យដីធ្លី ត្រូវបានផ្សព្វផ្សាយឲ្យអនុវត្តកម្មវិធីវាស់វែងបែងចែកដី និងប័ណ្ណកម្មសិទ្ធិដីលំនៅស្ថាន និងដីស្រែ ត្រូវបានចែកជូន។ រហូតមកទល់ពេលនេះ អាជ្ញាធរបានចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីចំនួន ២.៨៤៥.២៨២ សម្រាប់ ៥០០.០០០ គ្រួសារ។ ទាក់ទងនឹងការបណ្តេញចេញពីដី គណៈប្រតិភូបានបញ្ជាក់ថា មនុស្សមួយចំនួនមិនបានទទួលព័ត៌មានគ្រប់គ្រាន់ ហើយថារាជរដ្ឋាភិបាលត្រូវតែពិចារណាអំពីផលប្រយោជន៍ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ហើយមិនអាចទុកឲ្យផលប្រយោជន៍របស់មនុស្សភាគច្រើនធ្លាក់ជាចំណាប់ខ្មាំងរបស់មនុស្សភាគតិចនោះឡើយ។

12. គណៈប្រតិភូបានកត់សំគាល់ថា រាជរដ្ឋាភិបាលបានទទួលស្គាល់កម្មសិទ្ធិដីខុសច្បាប់ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលស្វែងរកទីតាំងស្របច្បាប់ដើម្បីរស់នៅ។ គណៈប្រតិភូបានបន្ថែមទៀតថា អ្នកតំណាងនានាត្រូវបានចាត់តាំងឲ្យការពារផលប្រយោជន៍របស់សហគមក្រីក្រ។ គណៈប្រតិភូក៏បានពន្យល់ផងដែរថា ជាទូទៅ ការជូនដំណឹងអំពីទីតាំងណាមួយត្រូវអភិវឌ្ឍន៍តែងតែប្រាប់ដល់អ្នករស់នៅទីនោះ យ៉ាងតិចមួយឆ្នាំមុនដែរ។

13. ទាក់ទងនឹងដីរបស់ជនជាតិដើម គណៈប្រតិភូបានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលមានគោលនយោបាយ បទបញ្ញា និងច្បាប់ ដើម្បីការពារ និងទទួលស្គាល់សិទ្ធិរបស់ពួកគេ។ អនុក្រឹត្យមួយត្រូវបានព្រាងឡើង ដោយផ្អែកលើគម្រោងសាកល្បងនៃការចុះបញ្ជីដីសម្រាប់ជនជាតិដើមបីសហគមន៍។ បន្ថែមពីនេះ កិច្ចពិគ្រោះយោបល់ ត្រូវបានធ្វើឡើងជាមួយអ្នកជំនាញការជាតិ និងអន្តរជាតិ ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងជាពិសេស ជាមួយជនជាតិដើមផ្ទាល់តែម្តង។

14. ទាក់ទងទៅនឹងនីតិរដ្ឋ គណៈប្រតិភូបានបញ្ជាក់ថារាជរដ្ឋាភិបាល បានបន្តអនុវត្តកំណែទម្រង់ស៊ីជម្រៅ លើបញ្ហាច្បាប់ និងតុលាការ។ រហូតមកទល់ពេលនេះ ច្បាប់ចំនួន ៤១៦ ត្រូវបានអនុម័តដើម្បីលើកកំពស់ក្របខ័ណ្ឌច្បាប់ និងពង្រឹងសមត្ថភាព ឯករាជ្យភាព និងភាពមិនលំអៀងនៃ ស្ថាប័នតុលាការ។ អាជ្ញាធរនឹងខិតខំបន្តទៀត ដើម្បីកែទម្រង់ច្បាប់ ដោយលើកទឹកចិត្តឲ្យមានការព្រាងច្បាប់ថ្មីៗ បង្កើតកម្មវិធីលើកកំពស់ការយល់ដឹងអំពីច្បាប់ និងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅគ្រប់កម្រិត។ គណៈប្រតិភូបានបន្ថែមទៀតថា រាជរដ្ឋាភិបាលក៏បានជំរុញផងដែរឲ្យអនុម័តច្បាប់ទាំងឡាយ ដែលទាក់ទងនឹងតុលាការ។

15. ដោយកត់សំគាល់ថា ការបោះឆ្នោតតំណាងរាស្ត្រ ដែលបានធ្វើឡើងកាលពីថ្ងៃ២៨ ខែកក្កដា ឆ្នាំ២០១៣ គណៈប្រតិភូបានបញ្ជាក់ថា គណបក្សនយោបាយទាំងអស់មានឱកាសប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានជួយសម្រួលដល់ការប្រើសេរីភាពនៃការសំដែងមតិ និងការប្រមូលផ្តុំជាសាធារណៈសម្រាប់ទាំងអស់គ្នា។ គជប ក៏បានលើកទឹកចិត្តផងដែរដល់អង្គការជាតិ និងអន្តរជាតិ ឲ្យចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន ដែលទាក់ទងនឹងការបោះឆ្នោត។ គណៈប្រតិភូបានកត់សម្គាល់ថា យុទ្ធនាការបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវបានធ្វើឡើងដោយរលូន ហើយថា អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិស្ទើរតែទាំងអស់ បានវាយតម្លៃជាវិជ្ជមានអំពីដំណើរការបោះឆ្នោតនេះ។

16. គណៈប្រតិភូបានលើកឡើងថា បន្ទាប់ពីបានទទួលអនុសាសន៍ពីប្រភពផ្សេងៗ ដូចជាអ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា រាជរដ្ឋាភិបាលបានផ្តល់ភារកិច្ចដល់ក្រសួងមហាផ្ទៃ រៀបចំសិក្ខាសាលាជាតិមួយនៅក្នុងឆមាសទីមួយនៃឆ្នាំ២០១៤ ជាមួយតំណាងនានាពីអង្គការនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ គណបក្សនយោបាយនានាដែលបានចុះបញ្ជី គជប សង្គមស៊ីវិល និងអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត។ គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីប្រមូលទស្សនៈ យោបល់ និងអនុសាសន៍ដើម្បីជួយដល់ការព្រាងកំណែទម្រង់ការបោះឆ្នោត។

17. គណៈប្រតិភូបានបញ្ជាក់ថា អាជ្ញាធរបានសង្កត់ធ្ងន់ពីតួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិល ថាជាដៃគូដ៏មានប្រសិទ្ធភាពមួយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះរាជរដ្ឋាភិបាលបានផ្តល់នូវការលើកទឹកចិត្តដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា និងស្វាគមន៍ការចូលរួមរបស់ពួកគេ នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេស និងការលើកស្ទួយប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

18. ទាក់ទងនឹងសិទ្ធិមានសមាគម គណៈប្រតិភូបានបញ្ជាក់ពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល មានគោលបំណងចែងពីបទដ្ឋាន និងលក្ខខណ្ឌនៃការចុះបញ្ជី ដែលនឹងជួយសម្រួលដល់សកម្មភាពរបស់សមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិនៅកម្ពុជា។ បន្ទាប់ពីមានការពិភាក្សាជាច្រើនដងជាមួយសមាគម អង្គការជាតិ និងអន្តរជាតិ អ្នកតំណាងនៃរដ្ឋដទៃទៀត សេចក្តីព្រាងច្បាប់នេះ ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីដែលត្រូវបានអនុម័តជាឯកច្ឆ័ន។

19. ទាក់ទងទៅនឹងសេរីភាពនៃការសំដែងមតិ គណៈប្រតិភូបានកត់សម្គាល់ថា តាមមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ បុគ្គលគ្រប់រូបអាចបញ្ចេញទស្សនៈរបស់ខ្លួន និងមានសិទ្ធិទទួលបានសេរីភាពនៃការបញ្ចេញមតិ។ គណៈប្រតិភូបានសង្កត់ធ្ងន់ថា រដ្ឋាភិបាល បានលើកទឹកចិត្តដល់កិច្ចពិភាក្សាក្នុងវេទិកាសាធារណៈ និងបានអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិល សំដែងទស្សនៈរបស់ខ្លួន ដោយសេរី។ ជាក់ស្តែង មានអង្គការក្រៅរដ្ឋាភិបាលនានា ដូចជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការអាដហុក អង្គការលីកាដូ អង្គការ NDI និង IRI ដែលបានផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិមនុស្ស និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សនៅទូទាំងប្រទេស។

20. គណៈប្រតិភូ បានពន្យល់ថា នៅក្នុងប្រទេសកម្ពុជា មានប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពចំនួន ៧២១ ស្ថានីយ៍វិទ្យុ១៣៩ ស្ថានីយទូរទស្សន៍១០៨ ទូរទស្សន៍ខ្សែកាប១២៧ និងបណ្តាញផ្សព្វផ្សាយសង្គមជាច្រើនរាប់មិនអស់ដទៃទៀតដែលបានផ្សព្វផ្សាយព័ត៌មានដោយគ្មានការត្រួតពិនិត្យ។ គណៈប្រតិភូ បានពន្យល់បន្ថែមថា ប្រជាពលរដ្ឋមានសិទ្ធិបង្កើតគេហទំព័រផ្ទាល់ខ្លួន និងផ្សព្វផ្សាយទស្សនៈរបស់ខ្លួនដោយសេរី។

21. ទាក់ទងនឹងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ NHRI គណៈប្រតិភូបានកត់សម្គាល់ថា គណៈកម្មាធិការមួយ ត្រូវបានតែងតាំង ដើម្បីព្រាងច្បាប់មួយ ប៉ុន្តែមិនមានដំណើរការទេ។ នៅក្នុងឆ្នាំ២០០៦ នាយករដ្ឋមន្ត្រី បានស្នើឲ្យអង្គការសង្គមស៊ីវិល ព្រាងច្បាប់មួយដោយផ្អែកលើគោលការណ៍ក្រុងប៉ារីស។ បន្ទាប់មក ក្រុមការងារមួយបានអនុវត្តផែនការសកម្មភាព ដើម្បីព្រាងច្បាប់

នេះ។ ថ្មីៗនេះ នាយករដ្ឋមន្ត្រី បានស្នើឲ្យមានការពិភាក្សាគ្នាបន្ថែមទៀតអំពីបញ្ហានេះ ជាមួយអង្គការសង្គមស៊ីវិល។ បន្ទាប់ពីកិច្ចពិគ្រោះយោបល់ទាំងនេះ សិក្ខាសាលាជាតិមួយនឹងត្រូវរៀបចំឡើង ដើម្បីប្រមូលគំនិត និងអនុសាសន៍ពីអ្នកជំនាញខាងច្បាប់ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីកែលម្អសេចក្ដីព្រាងនេះ មុននឹងត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីចាត់ការបន្ត។

22. ទាក់ទងទៅនឹងយន្តការបង្ការថ្នាក់ជាតិមួយស្ដីពីទារុណកម្ម គណៈប្រតិភូបានបញ្ជាក់ថា ដើម្បីឲ្យស្របតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម នៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយស្ដីពីការបង្កើតយន្តការនេះ។

23. គណៈប្រតិភូបានកត់សម្គាល់ថា នៅក្នុងខែធ្នូ ឆ្នាំ២០០៩ អនុគណៈកម្មាធិការប្រឆាំងទារុណកម្ម (SPT) បានមកធ្វើទស្សនកិច្ចនៅកម្ពុជាជាលើកដំបូង ហើយក្នុងខែធ្នូ ឆ្នាំ២០១៣ អនុគណៈកម្មាធិការនេះបានមកធ្វើទស្សនកិច្ចជាលើកទីពីរ។ សមាជិកអនុគណៈកម្មាធិការបានចុះទៅទស្សនកិច្ចនៅតាមពន្ធនាគារ និងប៉ុស្តិ៍នគរបាល និងបានរៀបចំសិក្ខាសាលាមួយស្ដីពីការបង្កើតយន្តការបង្ការថ្នាក់ជាតិនេះ។ ក្រសួងមហាផ្ទៃ និងការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានធ្វើការពិភាក្សាអំពីសេចក្ដីព្រាងច្បាប់នេះ ដើម្បីធានាថា សេចក្ដីព្រាងនេះស្របតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។

## ខ.កិច្ចសន្ទនាគ្នាទៅវិញទៅមក និងការឆ្លើយតបដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិញ

24. ក្នុងអំឡុងកិច្ចសន្ទនាគ្នា គណៈប្រតិភូចំនួន៧៦ បានធ្វើសេចក្ដីថ្លែងការណ៍។ អនុសាសន៍នានា ដែលបានធ្វើឡើងក្នុងអំឡុងកិច្ចសន្ទនានោះ នឹងមាននៅក្នុងផ្នែកទី២ នៃរបាយការណ៍នេះ។

25. ប្រទេសស្លូវេនី បានកោតសរសើរដល់វិធានការនានា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ និងសិទ្ធិស្ត្រី។ មានការព្រួយបារម្ភថា ច្បាប់ស្ត្រី អនុញ្ញាតឲ្យការបង្រៀននៅតាមសាលាអំពីទស្សនៈនៃតួនាទីរបស់ស្ត្រីនៅក្រោមគេ ហើយថាការអប់រំជាមូលដ្ឋាននៅតែមានលក្ខណៈមិនមែនកាតព្វកិច្ច។ ប្រទេសស្លូវេនី បានផ្ដល់អនុសាសន៍មួយចំនួន។

26. ប្រទេសអេស្ប៉ាញ បានសំដែងការព្រួយបារម្ភអំពីព្រឹត្តិការណ៍ថ្មីៗ ដែលបានបណ្ដាលឲ្យមានការស្លាប់មួយចំនួន។ កិច្ចខិតខំប្រឹងប្រែងដើម្បីធានាឯករាជ្យភាពនៃប្រព័ន្ធច្បាប់ នៅមិនទាន់គ្រប់គ្រាន់។ ស្ត្រីប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរនៅពេលស្វះស្វែងរកសិទ្ធិទទួលសេវាកម្មយុត្តិធម៌ ហើយជាញឹកញាប់ ត្រូវស្ថិតក្នុងស្ថានភាពដូចទាសភាពនៅក្នុងប្រទេសទីបី។ បញ្ហានានាទាក់ទងនឹងកម្ម

សិទ្ធិដីធ្លី និងការគ្រប់គ្រងនៅតែមានផលប៉ះពាល់អវិជ្ជមាន ជាពិសេសមកលើអ្នកក្រ។ ប្រទេសអេស្ប៉ាញបានផ្តល់អនុសាសន៍មួយចំនួន។

27. ប្រទេសស្រីលង្កាបានស្វាគមន៍វឌ្ឍនភាពដែលមានឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស ជាពិសេស នៅក្នុងសមភាពយេនឌ័រ មរណភាពកុមារ សុខភាពមាតា ការប្រយុទ្ធនឹងជំងឺឆ្លង ពលកម្មកុមារ និងការទទួលបានការអប់រំ។ ប្រទេសនេះបានកោតសរសើរដល់ការបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់ក្រុមដែលងាយរងគ្រោះ។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

28. រដ្ឋប៉ាឡេស្ទីនបានស្វាគមន៍កិច្ចខិតខំប្រឹងប្រែងលើកស្ទួយគោលការណ៍អប់រំសម្រាប់ទាំងអស់គ្នា និងដោះស្រាយបញ្ហាប្រឈមនានាដែលបានជួបប្រទះនៅក្នុងវិស័យសុខាភិបាល។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

29. ប្រទេសស៊ុយអែតបានអំពាវនាវឲ្យមានការស៊ើបអង្កេតដែលអាចជឿទុកចិត្តបានមួយទៅលើករណីបាញ់ប្រហារក្នុងខែមករា ឆ្នាំ២០១៣ និងការលុបចេញនូវបំរាមលើការប្រមូលផ្តុំដោយសន្តិវិធី។ ប្រទេសស៊ុយអែតបានសំដែងនូវការព្រួយបារម្ភថា សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធអ៊ីនធើណិត អាចរឹងបន្តឹងសេរីភាពនៃការបញ្ចេញមតិ។ ប្រទេសនេះបានគូសបញ្ជាក់ពីតម្រូវការសម្រាប់កំណែទម្រង់ប្រព័ន្ធច្បាប់និងប្រព័ន្ធបោះឆ្នោត។ ប្រទេសស៊ុយអែតបានផ្តល់អនុសាសន៍មួយ។

30. ប្រទេសស្វីសមានការព្រួយបារម្ភចំពោះការធ្លាក់ចុះនូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិមានសមាគម។ ប្រទេសនេះបានសំដែងការស្តោកស្តាយចំពោះកង្វះខាតនៃការធ្វើឲ្យប្រសើរឡើងដល់ឯករាជ្យភាពតុលាការ និងមានការបារម្ភដោយសារការចោទប្រកាន់អំពីការរើសអើងជាតិសាសន៍។ ប្រទេសស្វីសបានផ្តល់អនុសាសន៍មួយចំនួន។

31. ប្រទេសឥណ្ឌូនេស៊ីបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងអនុវត្តផែនការយុទ្ធសាស្ត្រអប់រំសំរាប់ឆ្នាំ២០០៩-២០១៣ លើកកម្ពស់សិទ្ធិសុខភាពប្រកបដោយសមធម៌ និងកាត់បន្ថយភាពក្រីក្រ។ ទោះជាយ៉ាងណាក្តី ប្រទេសនេះជឿថា នៅមានឱកាសសម្រាប់កែលម្អ នៅក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។ ប្រទេសឥណ្ឌូនេស៊ីបានផ្តល់អនុសាសន៍មួយចំនួន។

32. ប្រទេសទីម័រខាងកើតបានកត់សម្គាល់ថា សិទ្ធិក្នុងការទទួលបានសុខភាព គឺជាអាទិភាពយ៉ាងសំខាន់មួយសម្រាប់កម្ពុជា។ ប្រទេសនេះបានសរសើរដល់ការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយសុខភាព និងការបង្កើនថវិកាជាតិសម្រាប់សុខភាព។ ប្រទេសទីម័រខាងកើតបានផ្តល់អនុសាសន៍មួយចំនួន។

33. ប្រទេសទុយនេស៊ីបានស្វាគមន៍ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។ ប្រទេសនេះ បានកោតសរសើរដល់កិច្ចសហប្រតិបត្តិការជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ប្រទេសទុយនេស៊ីបានផ្តល់អនុសាសន៍មួយចំនួន។

34. ទួរមេនីស្ថានបានកោតសរសើរពីការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។ ប្រទេសនេះបានកោតសរសើរដល់ការចាត់វិធានការនានាដើម្បីគាំទ្រដល់ជនពិការ។ ប្រទេសទួរមេនីស្ថានបានផ្តល់អនុសាសន៍មួយចំនួន។

35. ចក្រភពអង់គ្លេស បានទទូចឲ្យរដ្ឋាភិបាល ធ្វើការស៊ើបអង្កេត ដែលអាចជឿទុកចិត្តបានទៅលើការបាញ់ប្រហារ កាលពីខែមករា ឆ្នាំ២០១៣ លុបចោលបំរាមនៃការប្រមូលផ្តុំដោយសន្តិវិធី និងផ្តោតលើការកែទម្រង់តុលាការ និងនយោបាយរយៈពេលវែង ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហាពុករលួយ និងការប្រព្រឹត្តិមិនគប្បីលើអ្នកទោសដោយតុលាការ។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

36. សហរដ្ឋអាមេរិកបានទទូចឲ្យរាជរដ្ឋាភិបាលកម្ពុជាលុបចោលបំរាមលើការប្រមូលផ្តុំដោយសន្តិវិធី បន្តពង្រឹងស្ថាប័នប្រជាធិបតេយ្យរបស់កម្ពុជា និងពន្លឿនកំណែទម្រង់ក្រមព្រហ្មទណ្ឌ។ ប្រទេសនេះ បានលើកទឹកចិត្តឲ្យកម្ពុជា ពង្រឹងយន្តការគ្រប់គ្រងដីធ្លី។ សហរដ្ឋអាមេរិកបានផ្តល់អនុសាសន៍មួយចំនួន។

37. អ៊ុយរុយហ្គាយបានស្វាគមន៍ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ការចាត់វិធានការនានាដើម្បីដាក់របាយការណ៍ជូនស្ថាប័នសន្ធិសញ្ញា សហប្រតិបត្តិការជាមួយអ្នករាយការណ៍ពិសេស និងការប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ អ៊ុយរុយហ្គាយបានផ្តល់អនុសាសន៍មួយចំនួន។

38. អ៊ុយបេគីស្ថានបានកោតសរសើរពីកិច្ចសហការជាមួយអ្នករាយការណ៍ពិសេស និងស្ថាប័នសន្ធិសញ្ញា និងបានស្វាគមន៍ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។ ប្រទេសនេះបានកត់សម្គាល់ពីវឌ្ឍនភាពនៅក្នុងវិស័យសមភាពយេនឌ័រ សិទ្ធិទទួលបានការអប់រំ និងសិទ្ធិកុមារ។ អ៊ុយបេគីស្ថានបានផ្តល់អនុសាសន៍មួយចំនួន។

39. វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវី) បានកត់សម្គាល់ពីការរួមចំណែកនៃការគ្រប់គ្រងលើការបែងចែក និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ តម្លាភាព និងនិរន្តរភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងការផាច់ចេញពីសង្គម។ ប្រទេសនេះបានស្វាគមន៍ពីការលើកស្ទួយការអប់រំដោយឥតគិតថ្លៃ អាហារូបករណ៍សម្រាប់អ្នកដែលត្រូវការ និងកម្មវិធីអក្ខរកម្ម។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

40. វៀតណាមបានវាយតម្លៃខ្ពស់ចំពោះការវិវឌ្ឍន៍ជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជា រួមទាំងការបោះឆ្នោតដោយត្រឹមត្រូវកាលពីពេលថ្មីៗនេះ និងវឌ្ឍនភាពនៃសិទ្ធិដីធ្លី ការប្រយុទ្ធនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សេរីភាពនៃការបញ្ចេញមតិ និងការធានាបានកាន់តែប្រសើរនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ប្រទេសនេះ បានផ្តល់អនុសាសន៍មួយចំនួន។

41. ប្រទេសអាល់ហ្សេរីបានកត់សម្គាល់ថា ការចូលជាសមាជិកនៃលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិមួយចំនួន កំពុងត្រូវបានពិចារណា ខណៈពេលដែលលិខិតូបករណ៍ដទៃទៀតត្រូវបានផ្តល់ សច្ចាប័នរួចហើយដោយកម្ពុជា។ ប្រទេសនេះបានស្វាគមន៍ចំពោះវឌ្ឍនភាពនៅក្នុងការលើកស្ទួយ សិទ្ធិជនពិការ។ ប្រទេសអាល់ហ្សេរីបានផ្តល់អនុសាសន៍មួយចំនួន។

42. ប្រទេសអង់ហ្គោឡាបានស្វាគមន៍វឌ្ឍនភាពរបស់កម្ពុជា ជាពិសេស នៅក្នុងវិស័យសុខាភិបាល និងអប់រំ និងសិទ្ធិស្ត្រី និងកុមារ។ ប្រទេសនេះបានកត់សម្គាល់ដោយពេញចិត្តនូវយុទ្ធសាស្ត្រនានា ដែលបានអនុវត្តដោយរដ្ឋាភិបាល ដើម្បីកែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ។ ប្រទេសអង់ហ្គោឡាបានផ្តល់អនុសាសន៍មួយ។

43. ប្រទេសម៉ិកស៊ិកូ បានកោតសរសើរដល់សហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងការដាក់របាយការណ៍ទៅស្ថាប័នសន្ធិសញ្ញា។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

44. ប្រទេសសឹង្ហបុរីបានកត់សម្គាល់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងនីតិរដ្ឋ និងការអនុវត្តកំណែទម្រង់តុលាការ តាមរយៈការអនុម័តច្បាប់នាពេលថ្មីៗនេះ។ ប្រទេសនេះក៏បានកត់សម្គាល់ផងដែរពីវឌ្ឍនភាព ក្នុងការកែលម្អការទទួលបានការអប់រំ ក្រោមផែនការយុទ្ធសាស្ត្រអប់រំសំរាប់ឆ្នាំ២០០៩-២០១៣។ ប្រទេសសឹង្ហបុរីបានផ្តល់អនុសាសន៍មួយចំនួន។

45. ប្រទេសអូទ្រីសបានរំលែកការព្រួយបារម្ភជាមួយអ្នករាយការណ៍ពិសេសអំពីការការពារសិទ្ធិមនុស្ស។ ប្រទេសនេះនៅតែបារម្ភអំពីការរឹបអូសដីធ្លី ដោយបញ្ជាក់ឡើងវិញពីអនុសាសន៍របស់ខ្លួន កាលពី UPR ជុំទីមួយ។ ប្រទេសអូទ្រីសបានផ្តល់អនុសាសន៍មួយចំនួន។

46. អាហ៊្សែរបៃហ្សង់បានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងដើម្បីធានាដល់សិទ្ធិទទួលបានការអប់រំដោយសមធម៌ ការបង្កើតកម្មវិធីសុខភាពមាតា និងទារក និងការពង្រឹងប្រព័ន្ធសុខាភិបាល។ ប្រទេសនេះក៏បានកត់សម្គាល់ផងដែរពីវិធានការនានា ដើម្បីលើកកម្ពស់សមភាព និងការប្រយុទ្ធប្រឆាំងនឹងការរើសអើងស្ត្រី។ ប្រទេសអាហ៊្សែរបៃហ្សង់បានផ្តល់អនុសាសន៍មួយចំនួន។

47. ប្រទេសបង់ក្លាដែសបានកត់សម្គាល់ពីអាទិភាពដែលបានផ្តល់លើការលើកកម្ពស់តួនាទីស្ត្រីក្នុងសង្គម។ ប្រទេសនេះក៏បានកត់សំគាល់ដែរថា ភាពក្រីក្រនៅតែជាឧបសគ្គធ្ងន់ធ្ងរមួយចំពោះការទទួលបានសិទ្ធិមនុស្សដោយពេញលេញដែលគួរតែត្រូវបានដោះស្រាយដោយការបង្កើតគោលនយោបាយ និងបរិស្ថានពាណិជ្ជកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានអំណោយផលមួយនៅថ្នាក់សកល។

48. ប្រទេសបែលហ្ស៊ិកបានសំដែងការព្រួយបារម្ភអំពីស្ថានភាពសិទ្ធិមនុស្សដែលកាន់តែអាក្រក់ឡើង នៅក្នុងតំបន់ជាច្រើន និងអំពីការវិវឌ្ឍថ្មីៗទាក់ទងទៅនឹងសេរីភាពនៃការបញ្ចេញមតិ ទោះបីជាមានការវិវឌ្ឍវិជ្ជមានខ្លះនៅក្នុងប្រទេសក៏ដោយ។ ប្រទេសបែលហ្ស៊ិកបានផ្តល់អនុសាសន៍មួយចំនួន។

49. ប្រទេសប៊ូតង់បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីរៀបចំប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ឲ្យស្របទៅនឹងស្តង់ដារអន្តរជាតិ និងដើម្បីលើកស្ទួយ និងការពារសិទ្ធិរបស់ក្រុមជនងាយរងគ្រោះ។ ប្រទេសនេះបានកត់សម្គាល់ថា បញ្ហាប្រឈមនៅតែមាននៅក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយ។

50. នៅក្នុងការឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងសិទ្ធិកុមារ ស្ត្រី និងមនុស្សចាស់ គណៈប្រតិភូបានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ដោយគូសបញ្ជាក់ថា កម្ពុជាប្តេជ្ញាចិត្តបង្កើនភាពតំណាងរបស់ស្ត្រី ក្នុងមុខតំណែងជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាល គណៈប្រតិភូបានកត់សំគាល់ពីអត្ថិភាពនៃកូតាសម្រាប់ស្ត្រីនៅក្នុងមុខតំណែងទាំងនេះ។

51. ទាក់ទងទៅនឹងប្រព័ន្ធបោះឆ្នោត គណៈប្រតិភូបានបញ្ជាក់ថា រាជរដ្ឋាភិបាលមានបំណងអនុវត្តកំណែទម្រង់ល្អិនល្អន់មួយនៃប្រព័ន្ធបោះឆ្នោតទាំងមូល ក្នុងពេលឆាប់ៗនេះ ដោយចាប់ផ្តើមជាមួយសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដែលគ្រោងនឹងធ្វើឡើងក្នុងត្រីមាសទីមួយ នៃឆ្នាំ ២០១៤ ដែលនឹងមានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗជាច្រើន។

52. ទាក់ទងទៅនឹងកំណែទម្រង់តុលាការ គណៈប្រតិភូបានបញ្ជាក់ពីក្ដីរំពឹងទុករបស់ខ្លួនថា រដ្ឋសភានឹងអនុម័តច្បាប់សំខាន់ៗជាមូលដ្ឋានចំនួនបីស្ដីពីតុលាការ ក្នុងត្រីមាសទីមួយ ឆ្នាំ២០១៤ នេះ។

53. ទាក់ទងនឹងបំរាមលើការធ្វើបាតុកម្ម និងការប្រមូលផ្ដុំសាធារណៈដែលបានដាក់តាំងពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ គណៈប្រតិភូបានបញ្ជាក់ថា បំរាមនេះគឺស្របតាមច្បាប់ស្ដីពីបាតុកម្មដោយសន្តិវិធី ហើយគឺជាការចាំបាច់ ដើម្បីស្តារសណ្តាប់ធ្នាប់ ស្ថិរភាព និងសន្តិសុខសង្គម សម្រាប់សង្គមទាំងមូល។

54. ទាក់ទងទៅនឹងកំណែទម្រង់តុលាការ ក្រោមអាណត្តិទីប្រាំនៃរដ្ឋសភា គណៈប្រតិភូបានបញ្ជាក់ឡើងវិញថា ច្បាប់សំខាន់ៗជាមូលដ្ឋានចំនួនបី ដែលគ្រោងនឹងដាក់ជូនរដ្ឋសភាក្នុងពេលឆាប់ៗនេះគឺ៖ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្ដីពីការរៀបចំតុលាការ និងច្បាប់ស្ដីពីកំណែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

55. ប្រទេសបូតស្វាណាបានកោតសរសើរដល់វិធានការច្បាប់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី និងលើកកំពស់ការយល់ដឹងអំពីយេនឌ័រ។ ប្រទេសនេះបានសំដែងការព្រួយបារម្ភអំពីរបាយការណ៍នានាទាក់ទងនឹងការយាយី ការបំភិតបំភ័យ អំពើហិង្សា ការចាប់ខ្លួនដោយមិនរើសមុខ ការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្ដុំ និងការរំលោភឯករាជ្យភាពរបស់តុលាការជាដើម។ ប្រទេសបូតស្វាណាបានផ្ដល់អនុសាសន៍មួយចំនួន។

56. ប្រទេសប្រេស៊ីលបានស្វាគមន៍ការផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិជនពិការ និងការបង្កើតផែនការសកម្មភាពអំពីពលកម្មកុមារ ប៉ុន្តែបានសំដែងការព្រួយបារម្ភចំពោះការរឹតបន្តឹងលើសេរីភាពនៃការបញ្ចេញមតិ និងការនៅតែមានជាបន្តនៃផ្នត់គំនិតដែលផ្អែកលើយេនឌ័រនៅក្នុងច្បាប់ស្រីដែលនៅតែបង្រៀនតាមសាលារៀននៅឡើយ។ ប្រទេសប្រេស៊ីលបានផ្ដល់អនុសាសន៍មួយចំនួន។

57. ប្រទេសប្រ៊ុយណេដារូសាឡឹមបានវាយតម្លៃខ្ពស់ចំពោះវិធានការនានា ដើម្បីលើកស្ទួយនិងការពារសិទ្ធិស្ត្រីនិងកុមារ និងប្រយុទ្ធនឹងការរើសអើងផ្លូវភេទ និងការប្តេជ្ញាចិត្តក្នុងការធ្វើឲ្យប្រសើរដល់សេវាសុខភាព។ ប្រទេសនេះបានស្វាគមន៍កិច្ចសហប្រតិបត្តិការដែលនៅតែបន្តរបស់កម្ពុជា ជាមួយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ប្រទេសប្រ៊ុយណេបានផ្ដល់អនុសាសន៍មួយ។

58. ប្រទេសកាណាដាបានចោទសួរពីវិធានការអ្វីខ្លះដែលបានធ្វើឡើងដើម្បីការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ រួមទាំងការធានាថា អាជ្ញាធរនឹងមិនប្រើក្រមព្រហ្មទណ្ឌ ឬអំពើហិង្សាដើម្បី

រីតបន្តឹងសិទ្ធិនោះទេ។ ប្រទេសនេះបានកត់សម្គាល់ពីវឌ្ឍនភាព ឆ្ពោះទៅរកការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សដែលទាក់ទងនឹងមរណភាពកុមារ និងសុខភាពមាតា។ ប្រទេសកាដាណាបានផ្តល់អនុសាសន៍មួយចំនួន។

59. ប្រទេសឆាដបានកត់សម្គាល់ពីការចូលជាសមាជិករបស់កម្ពុជា ក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិភាគច្រើន ហើយថា កម្ពុជាបានសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងស្ថាប័នសន្ធិសញ្ញានានា។ ប្រទេសឆាដបានស្វាគមន៍ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីធានាពីការទទួលបានរបស់ប្រជាពលរដ្ឋ នូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ប្រទេសឆាដបានផ្តល់អនុសាសន៍មួយ។

60. ប្រទេសឈីលីបានស្វាគមន៍ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកនៃសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួន និងការអនុម័តច្បាប់ដើម្បីកែលម្អក្របខ័ណ្ឌច្បាប់ និងស្ថាប័ន។ ប្រទេសនេះបានលើកទឹកចិត្តឲ្យកម្ពុជា បង្កើតវិធានការរបស់ខ្លួនបន្ថែមទៀតនៅក្នុងកិច្ចការនេះ។ ប្រទេសឈីលីបានផ្តល់អនុសាសន៍មួយចំនួន។

61. ប្រទេសចិនបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តអនុសាសន៍កាលពីលើកមុន និងបានអបអរសាទរកម្ពុជា ក្នុងការសម្រេចបានមុនកាលកំណត់នៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស ទាក់ទងទៅនឹងសមភាពយេនឌ័រ មរណភាពកុមារ សុខភាពមាតា ការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ និងការបង្កើតភាពជាដៃគូអភិវឌ្ឍន៍សកល។ ប្រទេសនេះបានស្វាគមន៍ពីការផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិ។ ប្រទេសចិនបានផ្តល់អនុសាសន៍មួយចំនួន។

62. ប្រទេសកូឡុំប៊ីបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីប្រយុទ្ធនឹងការជួញដូរមនុស្ស ដូចជាផែនការសកម្មភាពជាតិសំរាប់ឆ្នាំ២០១១-២០១៣ និងវិធានការដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងសន្ធិសញ្ញាក្រុងអូតាវ៉ាស្តីពីការហាមប្រាម ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស។ ប្រទេសកូឡុំប៊ីបានផ្តល់អនុសាសន៍មួយចំនួន។

63. សាធារណរដ្ឋកុងហ្គោបានកត់សម្គាល់ថា កម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួន ជាមួយស្ថាប័នសន្ធិសញ្ញា និងបានអនុម័តក្រមព្រហ្មទណ្ឌថ្មី និងច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី កាលពីពេលថ្មីៗនេះ។ ប្រទេសនេះបានលើកទឹកចិត្តឲ្យបន្តកិច្ចខិតខំប្រឹងប្រែងទៀត ដើម្បីធានាពីការទទួលបានសិទ្ធិមនុស្សដោយពេញលេញ។

64. ប្រទេសក្រូអាតបានស្វាគមន៍ដល់ការកែលំអច្បាប់ ដើម្បីធានាឲ្យមានការការពារកាន់តែប្រសើរដល់ជនពិការ ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។ ប្រទេសនេះបានសំដែងនូវការព្រួយបារម្ភចំពោះរបាយការណ៍ថ្មីៗនេះអំពីការវាយប្រហារលើសកម្មជន សមាជិកសហជីព និងអ្នកសារព័ត៌មាន។ ក្រូអាត បានផ្តល់អនុសាសន៍មួយចំនួន។

65. ប្រទេសគុយបាបានស្វាគមន៍ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងការអនុម័តផែនការយុទ្ធសាស្ត្រអប់រំ សំដៅធានាការទទួលបានជាសកលនូវការអប់រំ និងការកែលម្អកម្មវិធីសិក្សា។ ប្រទេសនេះបានកោតសរសើរដល់ផែនការសកម្មភាពលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ និងកែលម្អសុវត្ថិភាពនៅទីកន្លែងធ្វើការ។ ប្រទេសគុយបាបានផ្តល់អនុសាសន៍មួយចំនួន។

66. សាធារណរដ្ឋឆែកបានកត់សម្គាល់ថា ទោះបីជាខ្លួនបានផ្តល់អនុសាសន៍កន្លងមកក្តី ក៏សេរីភាពនៃការបញ្ចេញមតិក្នុងប្រទេសកម្ពុជា នៅតែមានការធ្លាក់ចុះ។ ប្រទេសនេះបានសំដែងនូវការព្រួយបារម្ភអំពីការបង្ក្រាបនាពេលថ្មីៗនេះ ទៅលើអ្នកតវ៉ាដោយសន្តិវិធីដែលបានបណ្តាលឲ្យមានការស្លាប់មួយចំនួន។ ប្រទេសឆែកបានផ្តល់អនុសាសន៍មួយចំនួន។

67. សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ បានកត់សម្គាល់ថា កម្ពុជាបានធ្វើឲ្យមានវឌ្ឍនភាពជាច្រើននៅក្នុងវិស័យសិទ្ធិមនុស្ស ជាពិសេស នៅក្នុងការអនុវត្តអនុសាសន៍ដែលបានទទួលយកក្នុងអំឡុងUPRជុំទីមួយ។ ប្រទេសនេះបានលើកទឹកចិត្តឲ្យកម្ពុជាបន្តកិច្ចខិតខំប្រឹងប្រែងជាវិជ្ជមានរបស់ខ្លួនតទៅទៀត។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

68. ប្រទេសដាណឺម៉ាក បានសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិ និងអំពើហិង្សាចំពោះអ្នកតវ៉ា និងការចាប់ខ្លួនអ្នកតវ៉ា។ ច្បាប់និងការអនុវត្តគួរតែស្របគ្នាជាមួយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ប្រទេសនេះបានស្វាគមន៍ការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម ប៉ុន្តែនៅតែបារម្ភចំពោះការខកខានក្នុងការអនុវត្តលិខិតូបករណ៍នេះឲ្យមានប្រសិទ្ធភាព។ ប្រទេសដាណឺម៉ាកបានផ្តល់អនុសាសន៍មួយចំនួន។

69. ប្រទេសឌ្យីប៊ូទី (Djibouti) បានអបអរសាទរដល់កម្ពុជាចំពោះសមិទ្ធផលទាំងអស់របស់ខ្លួន ក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

70. ប្រទេសអេក្វាឌ័រ បានស្វាគមន៍ដល់ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ប្រទេសនេះបានកោតសរសើរដល់ផែនការយុទ្ធសាស្ត្រអប់រំសំរាប់ឆ្នាំ២០០៩-២០១៣ និងផែនទីបង្ហាញផ្លូវដើម្បីលុបបំបាត់ពលកម្មកុមារត្រឹមឆ្នាំ២០១៦។ ប្រទេសអេក្វាឌ័របានផ្តល់អនុសាសន៍មួយចំនួន។

71. ប្រទេសអេហ្ស៊ីបបានស្វាគមន៍ដល់ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងការចាត់វិធានការនានា ដើម្បីធានាការអនុវត្តអនុសញ្ញានេះឲ្យមានប្រសិទ្ធភាព។ ប្រទេសនេះ បានកោតសរសើរដល់វិធានការកំណែទម្រង់តុលាការ ច្បាប់ថ្មីស្តីពីរបបសារព័ត៌មាន ផែនការសកម្មភាពដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ និងសហប្រតិបត្តិការជាមួយអ្នករាយការណ៍ពិសេស។ អេហ្ស៊ីបបានផ្តល់អនុសាសន៍មួយចំនួន។

72. ប្រទេសបារាំងបានស្វាគមន៍គណៈប្រតិភូកម្ពុជា និងបានថ្លែងអំណរគុណដល់គណៈប្រតិភូចំពោះការបង្ហាញរបាយការណ៍ជាតិរបស់ខ្លួន។ ប្រទេសបារាំងបានផ្តល់អនុសាសន៍មួយចំនួន។

73. ប្រទេសអាល្លឺម៉ង់បានកត់សម្គាល់ពីកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យប្រសើរនូវស្ថានភាពសិទ្ធិមនុស្សជាតិ ជាពិសេស ក្នុងការកាត់បន្ថយការជួញដូរមនុស្ស និងពលកម្មកុមារ។ ប្រទេសនេះនៅតែមានការព្រួយបារម្ភអំពីបំរាមបាតុកម្ម ការប្រើកម្លាំងប្រឆាំងអ្នកតវ៉ា និងការឃុំខ្លួនពួកគេ ដោយមិនបានទទួលមេធាវី។ ប្រទេសអាល្លឺម៉ង់បានផ្តល់អនុសាសន៍មួយចំនួន។

74. ប្រទេសហ្គាណាបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពដែលបានធ្វើឡើងនៅសាលាក្តីខ្មែរក្រហម/អវតក ដើម្បីផ្តន្ទាទោស និងបញ្ឈប់និទណ្ឌភាព។ ប្រទេសនេះបានទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងនីតិរដ្ឋ និងការគោរពឯករាជ្យភាព ភាពមិនលំអៀង និងដំណើរការក្តីត្រឹមត្រូវរបស់តុលាការ និងធានាមិនឲ្យមានការធ្វើទារុណកម្ម។ ប្រទេសហ្គាណាបានផ្តល់អនុសាសន៍១។

75. ប្រទេសហុងគ្រីបានកត់សម្គាល់ពីការចូលជាសមាជិក និងការផ្តល់សច្ចាប័ននៃលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា។ ប្រទេសនេះបានសំដែងនូវការព្រួយបារម្ភថា ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកនៅតែស្ថិតក្រោមការត្រួតត្រារបស់រដ្ឋាភិបាល និងចែករំលែកនូវការព្រួយបារម្ភជាមួយអ្នករាយការណ៍ពិសេសអំពីភាពមិនប្រក្រតីក្នុងការបោះឆ្នោត។ ប្រទេសហុងគ្រីបានផ្តល់អនុសាសន៍មួយចំនួន។

76. ប្រទេសឥណ្ឌាបានសំដែងនូវក្តីសង្ឃឹមថា កម្ពុជានឹងបន្តធ្វើឲ្យប្រសើរដល់ភាពមិនលំអៀងរបស់តុលាការ ដើម្បីពង្រឹងនីតិរដ្ឋ។ ប្រទេសនេះបានកោតសរសើរដល់ការសម្រេចបានមុនពេលកំណត់នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សទាំងប្រាំ និងការចាត់វិធានការនានា ដើម្បីផ្តល់ការទទួលបានសេវាថែទាំសុខភាព ការអប់រំ និងយុត្តិធម៌សង្គម។ ប្រទេសឥណ្ឌាបានផ្តល់អនុសាសន៍មួយចំនួន។

77. ប្រទេសថៃបានស្វាគមន៍ការរួមចំណែករបស់កម្ពុជា ទៅលើយន្តការសិទ្ធិមនុស្សអាស៊ានកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយអ្នករាយការណ៍ពិសេស និងការចូលជាសមាជិកនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ប្រទេសនេះបានទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងនានា ដើម្បីដោះស្រាយវិវាទដីធ្លី និងលើកកម្ពស់ការអប់រំ និងការថែទាំសុខភាព។ ប្រទេសថៃបានផ្តល់អនុសសាន៍មួយចំនួន។

78. ប្រទេសអ៊ីរ៉ង់(សាធារណរដ្ឋអ៊ីស្លាម) បានទទួលស្គាល់ទំហំនៃកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស រួមទាំងការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

79. អ៊ីរ៉ាក់ បានកោតសរសើរដល់ការចាត់វិធានការនានា ក្នុងនាមគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ កំណែទម្រង់តុលាការ ក្នុងគោលបំណងដាក់បញ្ចូលបទដ្ឋានអន្តរជាតិ ការលើកស្ទួយសេរីភាពនៃការបញ្ចេញមតិ វិធានការនានាប្រឆាំងអំពើពុករលួយ និងការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។ អ៊ីរ៉ាក់បានផ្តល់អនុសាសន៍មួយចំនួន។

80. ប្រទេសអៀរឡង់ដ៍បានទទូចឲ្យកម្ពុជាធានាការគោរពសិទ្ធិក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងបានគូសបញ្ជាក់ឡើងវិញពីការអំពាវនាវរបស់អ្នករាយការណ៍ពិសេស ឲ្យមានការបំភ្លឺផ្លូវច្បាប់ចំពោះការហាមប្រាមនេះរបស់រដ្ឋាភិបាល។ ប្រទេសនេះបានសំដែងការព្រួយបារម្ភ អំពីការប្រព្រឹត្តិមិនគប្បីជាបន្តរបស់រដ្ឋាភិបាល ទៅលើអ្នកការពារសិទ្ធិមនុស្ស ការត្រួតត្រាស្ទើរផ្តាច់មុខរបស់ខ្លួនលើប្រព័ន្ធផ្សព្វផ្សាយ និងការរឹតបន្តឹងលើសេរីភាពនៃការបញ្ចេញមតិ។ ប្រទេសអៀរឡង់ដ៍បានផ្តល់អនុសាសន៍មួយចំនួន។

81. ប្រទេសអ៊ីតាលីបានស្វាគមន៍វឌ្ឍនភាពនៅក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្សរួមទាំងវិធានការនានា ដើម្បីកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងលើកកំពស់ការយល់ដឹងអំពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។ ប្រទេសនេះបានសួរពីការចាត់វិធានការបន្ថែមទៀតដើម្បីប្រយុទ្ធនឹងអំពើពុករលួយ និងលើកកម្ពស់តម្លាភាព គណនេយ្យភាព ការមិនរើសអើង និងការចូលរួមប្រកបដោយអត្ថន័យ។ អ៊ីតាលីបានផ្តល់អនុសាសន៍មួយចំនួន។

82. ប្រទេសជប៉ុនបានស្វាគមន៍គោលនយោបាយព្យួរការផ្តល់ជំនួយសម្បទានសេដ្ឋកិច្ចថ្មី។ ប្រទេសនេះបានកោតសរសើរ ចំពោះការចូលជាសមាជិកនៃអនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ប្រទេសជប៉ុនបានផ្តល់អនុសាសន៍មួយចំនួន។

83. ប្រទេសកេនយ៉ាបានស្វាគមន៍ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងអនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។ ប្រទេសនេះក៏បានស្វាគមន៍ផងដែរនូវជំនួយ ដែលផ្តល់ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅក្នុងវិស័យកំណែទម្រង់ពន្ធនាគារ សេរីភាពជាមូលដ្ឋាន សិទ្ធិដីធ្លីនិងលំនៅស្ថាន នីតិរដ្ឋ និងអង្គជំនុំជម្រះវិសាមញ្ញ។ ប្រទេសកេនយ៉ាបានផ្តល់អនុសាសន៍មួយចំនួន។

84. សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវបានកត់សម្គាល់ថា កម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សភាគច្រើន និងបានទទួលភាពប្រសើរយ៉ាងរហ័សនៅក្នុងសូចនាករសង្គម។ ប្រទេសនេះបានលើកទឹកចិត្តឲ្យកម្ពុជា ពង្រឹងសហប្រតិបត្តិការរបស់ខ្លួនជាមួយអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត និងភាគីពាក់ព័ន្ធ។

85. ប្រទេសឡាតវីបានស្វាគមន៍ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន និងបានកត់សម្គាល់ដោយវាយតម្លៃខ្ពស់ថា កម្ពុជា គឺជាភាគីមួយនៃលក្ខន្តិកៈទីក្រុងរ៉ូម។ ឡាតវីបានផ្តល់អនុសាសន៍មួយចំនួន។

86. ប្រទេសម៉ាឡេស៊ី បានកោតសរសើរការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ កំណែទម្រង់ច្បាប់ វិធានការនានាប្រឆាំងអំពើពុករលួយ និងសមិទ្ធផលក្នុងវិស័យអប់រំ។ ប្រទេសនេះបានស្វាគមន៍វឌ្ឍនភាព នៅក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្នុងការប្រយុទ្ធនឹងការជួញដូរមនុស្ស។ ម៉ាឡេស៊ីបានផ្តល់អនុសាសន៍មួយចំនួន។

87. ប្រទេសម៉ូរីតានីបានកត់សម្គាល់ពីសារៈសំខាន់ ចំពោះការពង្រឹងក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលត្រូវការសម្រាប់ការលើកស្ទួយសិទ្ធិមនុស្ស។ ប្រទេសនេះបានកោតសរសើរការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។

88. អាហ្សង់ទីនបានកោតសរសើរការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ និងបានលើកទឹកចិត្តកម្ពុជា ឲ្យផ្តល់សច្ចាប័នសន្ធិសញ្ញាសិទ្ធិមនុស្សបន្ថែមទៀត។ ប្រទេសអាហ្សង់ទីនបានផ្តល់អនុសាសន៍មួយចំនួន។

89. ប្រទេសម៉ុងតេនេក្រូបានស្វាគមន៍ចំពោះការអនុម័តក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការអនុវត្ត ក្រមរដ្ឋប្បវេណី និងច្បាប់ប្រឆាំងអំពើពុករលួយ។ ប្រទេសនេះបានសួរថា តើកម្ពុជាបានសម្រួល ច្បាប់ស្រី ដើម្បីលុបចោលការនិយាយយោងណាមួយទៅលើតួនាទីទាបរបស់ស្ត្រីក្នុងសង្គម និងសួរ អំពីការអនុវត្តផែនការសកម្មភាព ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ ប្រទេស ម៉ុងតេនេក្រូ បានផ្តល់អនុសាសន៍មួយចំនួន។

90. ដោយនិយាយយោងទៅលើកិច្ចសហការរបស់កម្ពុជា ជាមួយយន្តការសិទ្ធិមនុស្សអន្តរ ជាតិ គណៈប្រតិភូបានចង្អុលបង្ហាញថា នៅក្នុងអំឡុងពេលដែលកម្ពុជាធ្វើជាប្រធានអាស៊ាន បាន អនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន កាលពីខែធ្នូ ឆ្នាំ២០១២។ គណៈប្រតិភូបានគូសបញ្ជាក់ ពីការខិតខំប្រឹងប្រែងយ៉ាងធំធេងរបស់កម្ពុជា ទាំងនៅទីក្រុងហ្សឺណែវ ពីការប្រើប្រាស់ជំនួយបច្ចេក ទេស និងការណែនាំរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងបានកត់សម្គាល់ពីកិច្ចសហការជាវិជ្ជមាន ជាមួយអ្នករាយការណ៍ពិសេស ដូចដែលបានបង្ហាញ នៅក្នុងទស្សនកិច្ចនាពេលថ្មីៗនេះរបស់អ្នករាយការណ៍ពិសេស ក្នុងខែមករា ឆ្នាំ២០១៤។ គណៈ ប្រតិភូបានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងបន្តកិច្ចសហការជាវិជ្ជមាននេះតទៅទៀត។

91. ឆ្លើយតបម្តងទៀតទៅនឹងសំណួរដែលបានលើកឡើងអំពីការបង្ក្រាបលើបាតុកម្ម នាពេល ថ្មីៗនេះ គណៈប្រតិភូបានកត់សម្គាល់ថា ទោះជារដ្ឋាភិបាលវាយតំលៃខ្ពស់ពីសារៈសំខាន់នៃសេរី ភាពក្នុងការបញ្ចេញមតិក្តី ក៏រដ្ឋាភិបាលជឿថា សិទ្ធិបែបនេះត្រូវតែប្រើប្រាស់នៅក្នុងក្របខ័ណ្ឌច្បាប់ ជាតិ និងអន្តរជាតិ ដោយមិនរំលោភលើសិទ្ធិអ្នកដទៃ ដូចជាសិទ្ធិមានសន្តិសុខ និងសិទ្ធិលើទ្រព្យ សម្បត្តិជាដើម។

92. ចំពោះសេរីភាពនៃការបញ្ចេញមតិតាមអ៊ីនធើណិតវិញ គណៈប្រតិភូបានកត់សម្គាល់ថា គ្មានការរឹតបន្តឹងណាមួយទេរហូតមកទល់ពេលនេះ ហើយថា ក្នុងការព្រាងច្បាប់ស្តីពីការគ្រប់គ្រង ប្រព័ន្ធអ៊ីធើណិត រដ្ឋាភិបាលនឹងគោរពអនុសាសន៍ដែលបានទទួល ហើយនឹងធ្វើតាមបទដ្ឋានអង្គការ សហប្រជាជាតិដែលពាក់ព័ន្ធ។

93. ទាក់ទងនឹងទស្សនវិស័យសម្រាប់ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោល ការណ៍ក្រុងប៉ារីស គណៈប្រតិភូបានកត់សម្គាល់ថា រដ្ឋាភិបាលនឹងចាត់ឲ្យដំណើរការទៅមុខទៀត ដោយផ្អែកលើអនុសាសន៍របស់អ្នករាយការណ៍ពិសេស និងនាយករដ្ឋមន្ត្រី និងដោយពិគ្រោះ យោបល់ជាមួយសង្គមស៊ីវិល។

94. ឆ្លើយតបទៅនឹងសំណួរអំពីរបាយការណ៍នានានៃការយាយី និងការបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស គណៈប្រតិភូបានគូសបញ្ជាក់ថា កម្ពុជាបានធ្វើការខិតខំយ៉ាងខ្លាំង ធ្វើការជាមួយសង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្សផង ដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រដ្ឋាភិបាល បានសហការយ៉ាងពេញលេញជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិល។

95. ទាក់ទងនឹងពលកម្មកុមារ គណៈប្រតិភូបានបញ្ជាក់ថា ក្រសួងសង្គមកិច្ច និងក្រសួងការងារ មានមន្ទីរនៅតាមខេត្ត-ក្រុង បានធ្វើការកំណត់រកករណីពលកម្មកុមារ។ ទោះបីជាយ៉ាងណាក្តី គណៈប្រតិភូបានកត់សម្គាល់ថា ករណីបែបនេះមិនសុទ្ធតែចំៗនោះទេ ដោយហេតុតែភាពក្រីក្រ ឪពុកម្តាយជារឿយៗមិនចង់ឲ្យកូនពួកគេត្រូវបានដកចេញពីរោងចក្រ។

96. ទាក់ទងនឹងបំរាមថ្មីៗលើការធ្វើបាតុកម្ម និងការប្រមូលផ្តុំជាសាធារណៈ គណៈប្រតិភូបានបន្ថែមទៀតថា បំរាមនេះត្រូវបានដាក់ចេញជាបណ្តោះអាសន្នតែប៉ុណ្ណោះ រហូតដល់ស្ថានភាពមានភាពប្រសើរឡើងវិញ ហើយថា បំរាមនេះអនុវត្តចំពោះតែការប្រមូលផ្តុំជាសាធារណៈ។ ក្នុងន័យនេះ គណៈប្រតិភូបានបញ្ជាក់ថា រាជរដ្ឋាភិបាលកំពុងតែធ្វើសេចក្តីច្បាប់មួយស្តីពីសិទ្ធិទទួលបានព័ត៌មាន។

97. ប្រទេសម៉ូរ៉ូកូបានស្វាគមន៍ចំពោះឆន្ទៈរបស់កម្ពុជា ក្នុងការធ្វើកំណែទម្រង់ការបោះឆ្នោត។ ប្រទេសនេះ បានកោតសរសើរដល់យន្តការដើម្បីការពារសិទ្ធិរបស់ជន ដែលត្រូវបានគេដកហូតសិទ្ធិសេរីភាព ជាពិសេស សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តិមិនគប្បី។ ប្រទេសម៉ូរ៉ូកូបានផ្តល់អនុសាសន៍មួយចំនួន។

98. ប្រទេសមីយ៉ាន់ម៉ាបានកត់សម្គាល់ដោយវាយតម្លៃខ្ពស់ថា កម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សចំនួនប្រាំ។ ប្រទេសនេះបានស្វាគមន៍កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ និងការអនុវត្តផែនការជាតិ "ការអប់រំសម្រាប់ទាំងអស់គ្នា"។ ប្រទេសមីយ៉ាន់ម៉ាបានផ្តល់អនុសាសន៍មួយចំនួន។

99. ប្រទេសនេប៉ាល់បានវាយតម្លៃខ្ពស់ចំពោះអាទិភាពដែលបានផ្តល់ដល់វិស័យអប់រំ សេវាសុខភាព និងការងារ និងបានស្វាគមន៍វិធានការនានា ដើម្បីហាមឃាត់ការរើសអើងប្រឆាំងស្ត្រី។ ប្រទេសនេះបានវាយតម្លៃខ្ពស់ចំពោះការចូលរួមប្រកបដោយស្ថាបនារបស់កម្ពុជា ជាមួយអ្នករាយការណ៍ពិសេស។ ប្រទេសនេប៉ាល់បានផ្តល់អនុសាសន៍មួយចំនួន។

100. ប្រទេសហូឡង់ដ៍បានស្វាគមន៍ពីសារៈសំខាន់ចំពោះសេរីភាពនៃការបញ្ចេញមតិ និងព័ត៌មាន និងសេរីភាពនៃសារព័ត៌មាន និងការបោះពុម្ពផ្សាយ។ ប្រទេសនេះបានសំដែងការព្រួយបារម្ភអំពីការរំលោភបំពានសេរីភាពនៃការប្រមូលផ្តុំ និងមានសមាគមដែលបានធ្វើឲ្យប៉ះពាល់ដល់សហជីព និងអង្គការសង្គមស៊ីវិល។ ប្រទេសហូឡង់ដ៍បានផ្តល់អនុសាសន៍មួយចំនួន។

101. ប្រទេសណូវែលហ្សេឡង់ដ៍បានសំដែងការព្រួយបារម្ភអំពីការចោទប្រកាន់ ចំពោះការលួចបន្លំ ភាពមិនប្រក្រតី និងអំពើហិង្សាមុនការបោះឆ្នោតឆ្នាំ២០១៣ និងបានសំដែងការព្រួយបារម្ភអំពីបញ្ហាប្រឈមចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងសកម្មជនសហជីព។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

102. ប្រទេសនីការ៉ាហ្គ័របានស្វាគមន៍ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ការអនុម័តច្បាប់ក្នុងស្រុក និងការអនុម័តកម្មវិធីអប់រំសុខភាព និងលំនៅស្ថាន។ ប្រទេសនេះបានលើកទឹកចិត្តឲ្យកម្ពុជាដាក់បញ្ចូលអនុសាសន៍ UPR ទៅក្នុងផែនការសកម្មភាព ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ នីការ៉ាហ្គ័របានផ្តល់អនុសាសន៍មួយចំនួន។

103. ប្រទេសប៉ាគីស្ថានបានកោតសរសើរការផ្តល់សច្ចាប័នសន្ធិសញ្ញាអន្តរជាតិ ការបង្កើតយន្តការការពារសិទ្ធិមនុស្ស និងការបង្កើតទំនាក់ទំនងដោយផ្ទាល់រវាងក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីខេត្ត-ក្រុង។ ប៉ាគីស្ថានបានផ្តល់អនុសាសន៍មួយចំនួន។

104. ប្រទេសប៉ូឡូញ បានលើកទឹកចិត្តឲ្យកម្ពុជា អនុវត្តតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលខ្លួនបានផ្តល់សច្ចាប័ន កាលពីពេលថ្មីៗនេះ។ ប្រទេសនេះបានសំដែងនូវការព្រួយបារម្ភអំពីស្ថានភាពនៅក្នុងវិស័យយុត្តិធម៌ និងអំពីការប្រើកម្លាំងហួសហេតុ ក្នុងអំឡុងពេលបាតុកម្មដែលទាក់ទងនឹងការបោះឆ្នោត និងការធ្វើកូដកម្មដោយកម្មករនៅក្នុងវិស័យកាត់ដេរ។ ប៉ូឡូញបានផ្តល់អនុសាសន៍មួយចំនួន។

105. ប្រទេសព័រទុយហ្គាល់បានស្វាគមន៍ការបង្កើតក្រុមប្រឹក្សាជាតិដើម្បីកុមារ និងបណ្តាញថ្នាក់តំបន់របស់ខ្លួន។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

106. សាធារណរដ្ឋកូរ៉េបានលើកទឹកចិត្តឲ្យកម្ពុជាពង្រឹងគោលនយោបាយរបស់ខ្លួន ដើម្បីឆ្លើយតបនឹងការរំពឹងទុករបស់ប្រជាពលរដ្ឋសម្រាប់សេរីភាព និងសិទ្ធិដែលត្រូវលើកកម្ពស់។ ប្រទេសនេះ បានសំដែងនូវការសោកស្តាយចំពោះការបាត់បង់ជីវិត ក្នុងឱកាសដែលកម្លាំងសន្តិសុខចាត់វិធានការហិង្សាប្រឆាំងនឹងអ្នកតវ៉ា នៅក្នុងវិស័យកាត់ដេរ។ សាធារណរដ្ឋកូរ៉េបានផ្តល់អនុសាសន៍មួយចំនួន។

107. ប្រទេសរ៉ូម៉ានីបានកត់សម្គាល់ថា កម្ពុជានៅតែប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរនៅឡើយ។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

108. សហព័ន្ធរុស្ស៊ីបានកត់សម្គាល់ពីកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធនឹងភាពក្រីក្រ ដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព និងដើម្បីធានាការទទួលបានកាន់តែប្រសើរនូវការថែទាំសុខភាព និងការអប់រំ។ ប្រទេសនេះបានផ្តល់អនុសាសន៍មួយចំនួន។

109. ប្រទេសសេនេហ្គាល់បានកោតសរសើរដល់ការអនុម័តផែនការសកម្មភាពជាតិ ដើម្បីកែលម្អលក្ខខណ្ឌរស់នៅរបស់កុមារ ស្ត្រី និងជនពិការ។ ប្រទេសនេះបានស្វាគមន៍វិធានការប្រយុទ្ធនឹងនិទណ្ឌភាព ជាពិសេស ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។ ប្រទេសសេនេហ្គាល់បានផ្តល់អនុសាសន៍មួយចំនួន។

110. ប្រទេសស៊ែបប៊ីបានកត់សម្គាល់ថា ការចាត់វិធានការនានាដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយដើម្បីពង្រឹងឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា និងដើម្បីកែទម្រង់ប្រព័ន្ធពន្ធនាគារ។ ស៊ែបប៊ីបានផ្តល់អនុសាសន៍មួយចំនួន។

111. ប្រទេសអូស្ត្រាលីបានសំដែងនូវការព្រួយបារម្ភអំពីការរឹតបន្តឹងលើសេរីភាពនៃការប្រមូលផ្តុំ និងមានសមាគម ជាពិសេស អំពើហិង្សាអសមាមាត្រនាពេលថ្មីៗ ប្រឆាំងនឹងអ្នកតវ៉ា រួមទាំងការឃុំខ្លួនដោយគ្មានការជំនុំជម្រះ។ ដោយកត់សម្គាល់ពីការចោទប្រកាន់អំពីភាពមិនប្រក្រតីនៃការបោះឆ្នោតក្នុងឆ្នាំ២០១៣ ប្រទេសនេះបានស្វាគមន៍ចំពោះការប្តេជ្ញាចិត្តដែលបានបញ្ជាក់រួចមកហើយ ដើម្បីធ្វើកំណែទម្រង់ការបោះឆ្នោត។ ប្រទេសអូស្ត្រាលីបានផ្តល់អនុសាសន៍មួយចំនួន។

112. ប្រទេសស្លូវ៉ាគីបានលើកទឹកចិត្តកម្ពុជាឲ្យផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សបន្ថែមទៀត។ ដោយនិយាយយោងដល់របាយការណ៍អំពីការបំភិតបំភ័យ និងការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ប្រទេសនេះបានអញ្ជើញកម្ពុជាឲ្យចូលរួមក្នុងកិច្ចសន្ទនាប្រកបដោយអត្ថន័យមួយជាមួយពួកគេ និងដើម្បីធានាការការពារពួកគេ។ ប្រទេសនេះបានទទូចឲ្យកម្ពុជា សហការយ៉ាងពេញលេញជាមួយអ្នករាយការណ៍ពិសេស អ្នកកាន់អាណត្តិនីតិវិធីពិសេសដទៃទៀត និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ ប្រទេសស្លូវ៉ាគីបានផ្តល់អនុសាសន៍មួយចំនួន។

113. ចំពោះរបាយការណ៍អំពីភាពមិនប្រក្រតីទាក់ទងនឹងការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣ គណៈប្រតិភូបានលើកជាឧទាហរណ៍នៃទឹកថ្នាំជ្រលក់ដៃ ហើយបានបញ្ជាក់ថា ទឹកថ្នាំនេះមានប្រសិទ្ធភាពខ្លាំងដែលវាជាប់នឹងម្រាមដៃរបស់អ្នកបោះឆ្នោតរយៈពេលមួយខែ បន្ទាប់ពីការបោះឆ្នោតរួច។ គណៈប្រតិភូបានច្រានចោលរបាយការណ៍អំពីភាពមិនប្រក្រតីជាមួយការចុះឈ្មោះអ្នកបោះឆ្នោត ក៏ដូចជាការចោទប្រកាន់ដែលថាការបោះឆ្នោតមិនមានតម្លាភាព ដោយបញ្ជាក់ថា វិធានការដ៏មានប្រសិទ្ធភាពនានា គឺមានរួចស្រេចហើយ ដើម្បីដោះស្រាយពីភាពខុសគ្នា ឬបញ្ហានានានោះ។

114. ទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីប្រយុទ្ធនឹងអំពើពុករលួយ គណៈប្រតិភូបានលើកឡើងពីច្បាប់ប្រឆាំងអំពើពុករលួយដែលត្រូវបានអនុម័ត ក្នុងឆ្នាំ២០១០ ស្របតាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ និងការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយថ្នាក់ជាតិ។ គណៈប្រតិភូបានកត់សម្គាល់ថា មានកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីផ្សព្វផ្សាយ និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ហើយជនល្មើសជាច្រើនត្រូវបានផ្តន្ទាទោស។

115. ទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អវតក) គណៈប្រតិភូបានបញ្ជាក់ថា កម្ពុជាអនុវត្តយ៉ាងតឹងរឹងតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ និងមិនដែលជ្រៀតជ្រែកក្នុងការងាររបស់ អ.វ.ត.ក ឡើយ។ សវនករជាតិដែលមានស្រេច ត្រូវបានចាត់ឲ្យត្រួតពិនិត្យតាមដាន និងទប់ស្កាត់អំពើពុករលួយនៅក្នុងស្ថាប័ននេះ។ គណៈប្រតិភូបានបន្ថែមថា កាលពីឆ្នាំកន្លងទៅ កម្ពុជាបានផ្តល់ថវិកាចំនួន១,៧លានដុល្លារអាមេរិក សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ រួមទាំងអគ្គិសនី និងមធ្យោបាយធ្វើដំណើរ និងថវិកាចំនួន១,៨លានដុល្លារទៀត សម្រាប់បៀវត្សរ៍របស់បុគ្គលិកជាតិ។

116. ទាក់ទងនឹងបញ្ហាដីធ្លី គណៈប្រតិភូបានពន្យល់ថា ច្បាប់ភូមិបាលនិងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ក៏ដូចជាយន្តការចាំបាច់នានាសំរាប់អនុវត្ត មានរួចជាស្រេចដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ នៅពេលដីធ្លីមានប័ណ្ណកម្មសិទ្ធិ មានតែតុលាការទេជាអ្នកដោះស្រាយវិវាទ។ បុគ្គលដែលរស់នៅលើដីរបស់រដ្ឋ ជាធម្មតាពួកគេត្រូវបានផ្តល់ជូនជម្រើសពីរ គឺទទួលយកគម្រោងអភិវឌ្ឍនៅនឹងកន្លែង ឬត្រូវផ្លាស់ទៅនៅកន្លែងផ្សេង។ សម្រាប់អ្នកដែលរស់នៅលើដីកម្មសិទ្ធិឯកជន រាជរដ្ឋាភិបាលជួយសម្រួលដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក ជាមួយក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធ។

117. ជាទីបញ្ចប់ គណៈប្រតិភូបានថ្លែងអំណរគុណដល់ដៃគូសន្ទនារបស់ខ្លួនចំពោះការផ្តល់អនុសាសន៍ទាំងអស់។ ដោយកត់សម្គាល់ថា អនុសាសន៍ទាំងនេះនឹងត្រូវបានកំណត់អាទិភាពដោយមានការបញ្ជាក់ពីពេលវេលាច្បាស់លាស់ គណៈប្រតិភូបានបញ្ជាក់ថា កម្ពុជានឹងព្រាងផែនការសកម្មភាពមួយ អំពីសិទ្ធិមនុស្ស ដោយផ្អែកលើអនុសាសន៍ទាំងនេះ។

## II. សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍

118. អនុសាសន៍ដែលបានតាក់តែងឡើងក្នុងអំឡុងពេលកិច្ចសន្ទនាគ្នានេះ និងមានរាយបញ្ជីខាងក្រោមនេះ ទទួលបានការគាំទ្រពីកម្ពុជា៖

118.1 *ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងចុះហត្ថលេខា និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (*ប្រាំង*)[១];

118.2 *ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី១ និងទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (*អូទ្រីស*)[២];

118.3 *ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (*ហុងគ្រី*)[៣]

118.4 *បន្តស្វែងរកលទ្ធភាព ដើម្បីពង្រីកការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ខ្លួនតាមរយៈការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនានា នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (*ឡាតវី*)[៤];

118.5 *ធានាពីការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំដល់កុមារទាំងអស់ នៅកម្ពុជា រួមទាំងដល់កុមារដែលមានដើមកំណើតជាជនជាតិវៀតណាម ព្រមទាំងចុះហត្ថលេខា និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ទាក់ទងនឹងនីតិវិធីបណ្តឹងបុគ្គល* (*ព័រទុយហ្គាល់*)[៥];

118.6 *ផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ* (*អេក្វាទ័រ*);

---

១. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
២. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
៣. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
៤. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
៥. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

118.7 ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ដែលខ្លួនបានចុះហត្ថលេខាក្នុងឆ្នាំ២០០៤ (អេហ្ស៊ីប);

118.8 ចាត់វិធានការចាំបាច់នានាដើម្បីផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ (ហ្គាណា)

118.9 ផ្តល់សច្ចាប័នលើអនុសញ្ញារបស់ UNESCO ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ (ប្រេស៊ីល);

118.10 ផ្តល់សច្ចាប័នលើអនុសញ្ញារបស់ UNESCO ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ (ឆាដ);

118.11 ចាត់វិធានការផ្តល់សច្ចាប័នលើអនុសញ្ញារបស់ UNESCO ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ (អូទ្រីស)

118.12 បន្តដំណើរការពីការចូលជាសមាជិកនៃលិខិតូបករណ៍សិទ្ធិមនុស្សស្នូលនានា (អារ៉ាប់រួម); 

118.13 អនុម័តវិធានការមានប្រសិទ្ធភាពនានា ដើម្បីប្រយុទ្ធនឹងវប្បធម៌ហិង្សា និងនិទណ្ឌភាព និងដើម្បីបង្កើតយន្តការបង្ការថ្នាក់ជាតិមួយដែលឯករាជ្យ និងមានធនធានគ្រប់គ្រាន់ យោងតាមលក្ខខណ្ឌតម្រូវនៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម (អាល្លឺម៉ង់);

118.14 ធានាការអនុវត្តដោយពេញលេញ នូវបទប្បញ្ញត្តិដែលបានអនុម័តនាពេលថ្មីៗ ទាក់ទងនឹងក្រមព្រហ្មទណ្ឌ (ម៉ុងតេណេក្រូ);

118.15 ពិនិត្យក្រមព្រហ្មទណ្ឌឡើងវិញ ដើម្បីធានាថា ក្រមនេះស្របគ្នានឹងកាតព្វកិច្ចរបស់កម្ពុជា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ និងចាត់វិធានការចាំបាច់នានា ដើម្បីធ្វើវិសោធនកម្ម ឬលុបចោលមាត្រាណាដែលមិនឆ្លើយតបនឹងកាតព្វកិច្ចទាំងនេះ (កាណាដា);

118.16 កែសម្រួលក្រមព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យវាស្របនឹងស្តង់ដារអន្តរជាតិ និង កាតព្វកិច្ចរបស់កម្ពុជា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (បែលហ្សិក);

118.17 បង្កើតច្បាប់មួយស្តីពីសេរីភាពទទួលព័ត៌មាន ស្របតាមស្តង់ដារអន្តរជាតិ (បែលហ្សិក)

118.18 អនុម័តវិធានការច្បាប់ និងវិធានការដទៃទៀត ដែលលើកកម្ពស់ការទទួល បានសេរីភាពនៃការបញ្ចេញមតិ (បុតស្វាណា);

118.19 ចាត់វិធានការដើម្បីធានាថា ច្បាប់កម្ពុជាអនុញ្ញាតឲ្យគណបក្សនយោបាយ ទាំងអស់ សហជីព និងក្រុមសង្គមស៊ីវិលដទៃទៀត ប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីទទួល បានសេរីភាពនៃការបញ្ចេញមតិ មានសមាគម និងការប្រមូលផ្តុំដោយសន្តិវិធី ហើយថា បាតុកម្មដោយសន្តិវិធី អាចកើតឡើងដោយសុវត្ថិភាព និងដោយគ្មានការភ័យខ្លាច ពីការ បំភិតបំភ័យ ឬការប្រើកម្លាំងហួសហេតុពីខាងភាគីអាជ្ញាធរកម្ពុជា។ (កាណាដា);

118.20 កែសម្រួលក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ដទៃទៀត ដើម្បីឲ្យច្បាប់ទាំងនេះ ស្របតាមស្តង់ដារសេរីភាពនៃការបញ្ចេញមតិជាអន្តរជាតិនិងទប់ស្កាត់ការយាយីដល់អ្នក ការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាល (សាធារណរដ្ឋឆេក);

118.21 ចាត់វិធានការដើម្បីឲ្យច្បាប់ និងការប្រតិបត្តិរបស់កម្ពុជា ស្របតាមស្តង់ដារ សិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ ទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ រួមទាំង សេរីភាពសារព័ត៌មាន (អៀរឡង់ដ៍);

118.22 ការពារប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យ ដូចជា តាមរយៈការលុបចោល មាត្រា៣០៥នៃក្រមព្រហ្មទណ្ឌ និងមាត្រា១៣នៃច្បាប់ស្តីពីសារព័ត៌មាន (ព័រទុយហ្គាល់)[៦];

---

៦. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

118.23 ចាត់វិធានការចាំបាច់នានា ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ជុំវិញការបោះឆ្នោត ក្នុងគោលបំណងធានាថា ការបោះឆ្នោតនាពេលអនាគត មានលក្ខណៈសេរី និងយុត្តិធម៌ ដែលអនុញ្ញាតឲ្យពលរដ្ឋកម្ពុជា មានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេចនានា ដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ និងដើម្បីជ្រើសរើសមន្ត្រីដែលឆ្លុះបញ្ចាំង និងឆ្លើយតប ដោយប្រសិទ្ធភាពទៅនឹងតម្រូវការរបស់ពួកគេ (កាណាដា);

118.24 អនុវត្តសេចក្តីព្រាងច្បាប់ចំនួនបីដែលមានគោលបំណងលើកកម្ពស់ឯករាជ្យភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ នៅពេលអនុម័តរួច (ព័រទុយហ្គាល់);

118.25 អនុវត្ត និងពង្រឹងគោលនយោបាយ និងច្បាប់នានា ដើម្បីការពារ និងលើកស្ទួយសិទ្ធិជនពិការ និងធានាថា យន្តការទាំងនេះ មានអភិក្រមផ្អែកលើសិទ្ធិមនុស្ស ដែលមានសង្គតិភាពជាមួយអនុសញ្ញាសិទ្ធិជនពិការ និងដោយពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល (កូឡុំប៊ី);

118.26 អនុម័តនិងអនុវត្តច្បាប់ដែលហាមឃាត់រាល់ទម្រង់នៃការប្រព្រឹត្តិមិនគប្បីលើ កុមារ និងដែលការពារពួកគេពីពលកម្មដោយបង្ខំ ការកេងប្រវ័ញ្ចផ្លូវភេទ និងការបំពាន (ព័រទុយហ្គាល់);

118.27 បន្តកំណែទម្រង់ច្បាប់និងស្ថាប័នដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស(នេប៉ាល់)

118.28 បន្តពង្រឹងសមត្ថភាពស្ថាប័នជាតិរបស់ខ្លួន នៅក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស រួមទាំងតាមរយៈការបញ្ចប់ដំណើរការនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ឥណ្ឌូនេស៊ី);

118.29 បង្កើតឲ្យបានឆាប់នូវស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ទុយនេស៊ី);

118.30 បង្កើតស្ថាប័នឯករាជ្យមួយទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទីក្រុងប៉ារីស (អាល់ហ្សេរី);

118.31 ត្រូវបង្កើយការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (អេហ្ស៊ីប);

118.32 ពិចារណាពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ឥណ្ឌា);

118.33 បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ (ថៃ)

118.34 បង្កើនកិច្ចខិតខំប្រឹងប្រែងបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ឈីលី)

118.35 បន្តវិធានការវិជ្ជមានដែលខ្លួនបានដាក់ចេញកន្លងមក ដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ដោយផ្អែកលើគោលការណ៍ទីក្រុងប៉ារីស (ម៉ាឡេស៊ី);

118.36 បង្កើតស្ថាប័នជាតិមួយសម្រាប់លើកស្ទួយ និងការពារសិទ្ធិមនុស្សស្របតាមគោលការណ៍ទីក្រុងប៉ារីស (ម៉ូរ៉ុកកូ);

118.37 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (ប៉ាគីស្ថាន);

118.38 បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (អូស្ត្រាលី);

118.39 ធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសិទ្ធិមនុស្ស (ទួកមេនីស្ថាន)

118.40 ពង្រឹងកិច្ចសហប្រតិបត្តិការ និងកិច្ចសន្ទនាប្រកបដោយន័យស្ថាបនាផ្នែកសិទ្ធិមនុស្ស រួមទាំងតាមរយៈគណៈកម្មការសិទ្ធិមនុស្សអាស៊ាន និងជាមួយស្ថាប័ន និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធ (វៀតណាម);

118.41 ស្វែងរកការគាំទ្រពីសហគមន៍អន្តរជាតិក្នុងក្របខ័ណ្ឌជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តសកម្មភាពនានា ដែលទាក់ទង នឹងសិទ្ធិមនុស្ស ឲ្យបានទាន់ពេលវេលា (អង់ហ្គោឡា);

118.42 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដល់ការអប់រំ និងការបណ្តុះបណ្តាលសិទ្ធិមនុស្ស នៅគ្រប់កម្រិត រួមទាំង មន្ត្រីរដ្ឋាភិបាល (ប៉ាគីស្ថាន);

118.43 គាំទ្រដល់អភិក្រមដែលតម្រង់ទិសគ្រួសារសម្រាប់កិច្ចការពារសិទ្ធិកុមារ និងអនុវត្តគោលនយោបាយជាតិដែលមានស្រាប់ នៅក្នុងន័យនេះ (សែបប៊ី);

118.44 ពិចារណាសហប្រតិបត្តិបន្ថែមទៀតជាមួយយន្តការត្រួតពិនិត្យសិទ្ធិមនុស្សអន្តរជាតិ រួមទាំងស្ថាប័នសន្ធិសញ្ញា និងនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស(ទួកមេនីស្ថាន)

118.45 បន្តសហការជាមួយអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងអនុវត្តអនុសាសន៍របស់គាត់ (អូទ្រីស);

118.46 ខិតខំរក្សាទំនាក់ទំនងការងារប្រកបដោយន័យស្ថាបនាជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាទាក់ទងនឹងឯករាជ្យភាពរបស់គាត់ និងរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (បែលហ្ស៊ិក);

118.47 សហការយ៉ាងពេញលេញ ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងទទួលយកសំណើទស្សនកិច្ចដោយអ្នករាយការណ៍ពិសេសនានា (ស្វីស);

118.48 បន្តជំរុញកិច្ចសហប្រតិបត្តិរបស់ខ្លួនជាមួយការិយាល័យឧត្តមស្នងការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងយន្តការនានារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (កេនយ៉ា);

118.49 បន្តកិច្ចខិតខំប្រឹងប្រែងថែមទៀតដើម្បីបង្កើន ការយល់ដឹងអំពីសមភាពយេនឌ័រ និងប្រយុទ្ធនឹងការរើសអើងប្រឆាំងស្ត្រី (ស្វូវេនី);

118.50 អនុវត្តពល់វិធានការរួមទាំងយុទ្ធនាការបង្កើនការយល់ដឹងថ្នាក់ជាតិ និងកិច្ចខិតខំប្រឹងប្រែងសំដៅកែប្រែ ឬលុបបំបាត់ឥរិយាបទបុរសជាធំ និងផ្នត់គំនិតនានាដែលរើសអើងប្រឆាំងស្ត្រី រួមទាំងឥរិយាបទ និងផ្នត់គំនិតទាំងឡាយដែលផ្អែកលើច្បាប់ស្រី (អ៊ុយរុយហ្គាយ);

118.51 បន្តវឌ្ឍនភាពរបស់ខ្លួននៅក្នុងការលើកស្ទួយ និងការការពារសិទ្ធិស្ត្រី ដោយពង្រឹងយន្តការស្ថាប័ន និងការអនុវត្តច្បាប់ ដែលកំពុងត្រូវបានលើកកំពស់ជាវិជ្ជមាន (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា));

118.52 បន្តកិច្ចខិតខំប្រឹងប្រែងលើការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (អាល់ហ្សេរី);

118.53 ជំរុញច្បាប់ស្តីពីសមភាពយេនឌ័រទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ មរតក និងអាពាហ៍ពិពាហ៍ (ម៉ិកស៊ិក្វ);

118.54 បន្តវិធានការរបស់ខ្លួនអំពីយុទ្ធនាការបង្កើនការយល់ដឹង និងវិធានការចាំបាច់ដទៃទៀត ទាក់ទងនឹងការលើកកម្ពស់សមធម៌ក្នុងសង្គម និងការលុបបំបាត់នូវការរើសអើងប្រឆាំងស្ត្រី (អាហ្សែបៃហ្សង់);

118.55 បន្តផ្តល់ភាពអង់អាចដល់ស្ត្រី កុមារ និងក្រុមដែលងាយរងគ្រោះដទៃទៀតក្នុងសង្គម (នេប៉ាល់);

118.56 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី (ប៉ាគីស្ថាន);

118.57 បន្តប្រយុទ្ធនឹងការរើសអើងដែលទទួលរងដោយកុមារនៃក្រុមងាយរងគ្រោះ និងក្រុមងាយរងគ្រោះ និងលុបបំបាត់ផ្នត់គំនិតដែលផ្អែកលើយេនឌ័រ។ ស្របគ្នានេះដែរ ធានាការបន្តផែនការអប់រំជាយុទ្ធសាស្ត្រ សំរាប់ឆ្នាំ២០០៩-២០១៣ ដើម្បីផ្តល់ឱកាសដូចគ្នាដល់កុមារ និងយុវជនទាំងអស់ ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ជំនឿនយោបាយ កាលៈទេសៈនៃដើមកំណើត និងលក្ខខណ្ឌសង្គម (កូទ្ឌីវ័រ)[៧];

118.58 បង្កើតលក្ខខណ្ឌ ដែលមានលក្ខណៈអំណោយផល ដល់ការអនុគ្រោះអន្តរជនជាតិនៅកម្ពុជា សម្រាប់អនាគតប្រជាធិបតេយ្យរបស់ប្រទេស (ស្វីស);

118.59 បន្តជាមួយវិធានការនានា ដើម្បីធានាការចុះបញ្ជីកំណើតកុមារ ដោយគ្មានការរើសអើងនឹងកុមារទេសន្តរប្រវេសន៍ និងបន្តពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់នីតិវិធីនៃការទទួលបានសញ្ជាតិ (អាហ្សង់ទីន);

118.60 ពិចារណាចាត់វិធានការចាំបាច់ដើម្បីកែលម្អស្ថានភាពពន្ធនាគារបន្ថែមទៀត (ឥណ្ឌា);

118.61 ចាត់វិធានការនានាដើម្បីជៀសវាងការប្រើកម្លាំងហួសហេតុ និងធានាថាលក្ខខណ្ឌនៃការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន ស្របតាមស្តង់ដារអន្តរជាតិ (បែលហ្សិក)[៨]

118.62 ចាត់គ្រប់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធនឹងអំពើហិង្សា និងការបំពានផ្លូវភេទលើស្ត្រី និងកុមារ រួមទាំងការរំលោភសេពសន្ថវៈ ដោយលើកស្ទួយយន្តការប្រកបដោយប្រសិទ្ធភាពមួយដើម្បីទទួល និងស៊ើបអង្កេតពាក្យបណ្តឹង អំពីអំពើហិង្សាផ្លូវភេទ ហើយផ្តល់ដល់ជនរងគ្រោះ នូវជំនួយផ្លូវចិត្ត និងផ្នែកសុខភាព (អ៊ុយរុយហ្គាយ);

៧. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។
៨. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

118.63 ធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីទប់ស្កាត់ និងដាក់ទោសទណ្ឌអំពើហិង្សា រួមទាំងការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ និងយកចិត្តទុកដាក់ជាពិសេសដល់គ្រួសារដែលងាយរងគ្រោះបំផុត ដែលរស់នៅក្នុងបរិដ្ឋានក្រីក្រ (អ៊ីតាលី);

118.64 បង្កើនយុទ្ធនាការលើកកំពស់ការយល់ដឹងអំពីសិទ្ធិស្ត្រី និងកុមារ ដោយមានការចូលរួមពីអ្នកសារព័ត៌មាន និងវិជ្ជាជីវៈផ្សព្វផ្សាយព័ត៌មាន ជាជាក្រុមគោលដៅមួយក្នុងចំណោមក្រុមគោលដៅនានារបស់ខ្លួន (អ៊ីតាលី);

118.65 កែទម្រង់ច្បាប់ជាតិ ក្នុងគោលបំណងកែលម្អកិច្ចការពារកុមារ និងស្ត្រី ពីអំពើហិង្សា និងសំខាន់បំផុត គឺពល់អំពើហិង្សាក្នុងគ្រួសារ (សហព័ន្ធរុស្ស៊ី);

118.66 ចាត់វិធានការចាំបាច់នានា ដើម្បីធានាថា កុមារ និងអនីតិជននៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា និងមជ្ឈមណ្ឌលយុវជន ទោះយ៉ាងណាក៏ដោយ មិនត្រូវដាក់ឲ្យទៅជាកន្លែងធ្វើទារុណកម្ម ឬការប្រព្រឹត្តមិនគប្បីឡើយ ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (បែលហ្ស៊ិក);

118.67 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការលើកស្ទួយ និងការពារសិទ្ធិកុមារ រួមទាំង ការបង្កើយ និងការអនុវត្តសេចក្តីព្រាងថ្មីនៃផែនការជាតិ ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ សម្រាប់ឆ្នាំ២០១៣-២០១៨ (ឥណ្ឌូនេស៊ី);

118.68 ធានាការគោរពដោយពេញលេញនូវច្បាប់ស្តីពីពលកម្មកុមារ និងអនុវត្តផែនការសកម្មភាពជាតិរបស់ខ្លួន ស្តីពីការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ពង្រឹងច្បាប់ដែលហាមឃាត់ពលកម្មកុមារ ដោយផ្តល់អាទិភាពទៅលើស្ថានភាពកុមារធ្វើការបំរើតាមផ្ទះ បង្កើនចំនួននៃការចុះអធិការកិច្ចការងារ និងធានាពីការផាកពិន័យ និងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ចំពោះជនណាដែលប្រើពលកម្មកុមារដោយខុសច្បាប់ (អ៊ុយរុយហ្គាយ)

118.69 ពង្រឹងវិធានការប្រយុទ្ធនឹងពលកម្មកុមារ និងការកេងប្រវ័ញ្ចលើកុមារ (អាល់ហ្សេរី

118.70 បន្តកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ និងដើម្បីកែលម្អស្តង់ដារសុវត្ថិភាពនៅកន្លែងធ្វើការ (គុយបា);

118.71 អនុវត្តផែនការសកម្មភាព ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ (អ៊ីរ៉ាក់);

118.72 ប្រយុទ្ធប្រឆាំងនឹងបញ្ហានៃការរំលោភសេពសន្ថវៈ និងពេស្យាចារលើអនីតិជន ដោយធានាពីការអនុវត្តដោយពេញលេញនូវច្បាប់នានា ដែលដាក់ទោសដល់អំពើរំលោភបំពាន និងអាជីវកម្មផ្លូវភេទ (បែលហ្ស៊ិក);

118.73 តាក់តែងយន្តការគ្រប់គ្រាន់មួយសម្រាប់ជួយកុមារអនាថា ដើម្បីឲ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ពីជំនួយ និងសេវាសមាហរណកម្មឡើងវិញ (ឌ្ស៊ីប៊ូទី);

118.74 បង្កើនកិច្ចខិតខំប្រឹងប្រែងលើប្រព័ន្ធការពារកុមារ ជាពិសេស កុមារដែលស្ថិតក្នុងក្រុមឯកោនិងក្រុមងាយរងគ្រោះ (អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម));

118.75 បន្តកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស(អ៊ុយបេគីស្ថាន);

118.76 បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (អេក្វាឌ័រ);

118.77 បន្តចាត់វិធានការចាំបាច់នានា ដើម្បីប្រយុទ្ធនឹងការជួញដូរមនុស្ស និងពលកម្មកុមារដោយប្រសិទ្ធភាព (អាល្លឺម៉ង់);

118.78 បន្តខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស កុមារ (នីការ៉ាហ្គ័រ);

118.79 អនុវត្តដោយពេញលេញនូវក្របខ័ណ្ឌសម្រាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលបានកំណត់នៅក្នុងរបាយការណ៍ខែកញ្ញា ឆ្នាំ២០១០ ដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (អេស្ប៉ាញ);

118.80 ជានាថា កិច្ចខិតខំប្រឹងប្រែងអំពីកំណែទម្រង់ច្បាប់ ត្រូវបន្តដោយគ្មានការរារាំង (ស៊ុយអែត);

118.81 បង្កើនកិច្ចខិតខំប្រឹងប្រែង សំដៅពង្រឹងឯករាជ្យភាពតុលាការ និងប្រព័ន្ធផ្សព្វផ្សាយ (អ៊ីតាលី);

118.82 ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាឯករាជ្យភាពតុលាការ ដោយគ្មានការត្រួតត្រា ឬការជ្រៀតជ្រែកនយោបាយ (ស្វីស);

118.83 បង្កើតកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលផ្តល់យន្តការធានាឯករាជ្យប្រព័ន្ធយុត្តិធម៌ និងប្រសិទ្ធភាពនៃស្ថាប័នដែលទទួលខុសត្រូវក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ (បែលហ្ស៊ិក);

118.84 បន្តដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ រួមទាំងការអនុវត្តវិធានការនានាដើម្បីពង្រឹងស្ថាប័ន និងធានាឯករាជ្យភាពរបស់ស្ថាប័នទាំងនោះ (ឈីលី);

118.85 ចាត់វិធានការនានាដែលលើកកម្ពស់ឯករាជ្យភាពតុលាការ ទាំងតាមច្បាប់ទាំងតាមការអនុវត្តជាក់ស្តែង (បុតស្វានណា);

118.86 ពង្រឹងស្ថាប័នតុលាការ និងស្ថាប័នសិទ្ធិមនុស្សជាតិរបស់ខ្លួនបន្ថែមទៀតដើម្បីធានាឯករាជ្យភាពនៃស្ថាប័នទាំងនេះ ឲ្យមានប្រសិទ្ធភាព (កេនយ៉ា);

118.87 អនុវត្តកំណែទម្រង់ដែលពាក់ព័ន្ធនានា ដែលធានាឯករាជ្យភាព និងភាពមិនលំអៀងនៃតុលាការ និងធានាថា ស្ថាប័ននេះមិនស្ថិតក្រោមការត្រួតត្រា និងការជ្រៀតជ្រែកនយោបាយ (ប៉ូឡូញ);

118.88 អនុម័ត និងអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីអង្គការចាត់តាំងតុលាការ និងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានាឯករាជ្យភាពនៃប្រព័ន្ធតុលាការ (បារាំង);

118.89 អនុម័តគ្រប់វិធានការចាំបាច់ ដើម្បីធានាពីឯករាជ្យភាពតុលាការ រួមទាំងតាមរយៈការអនុវត្តដោយប្រសិទ្ធភាពនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ (ស្លូវ៉ាគី);

118.90 ពន្លឿនដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹង និងធានាឯករាជ្យភាពតុលាការ ព្រមទាំងដើម្បីដោះស្រាយបញ្ហាពុករលួយ នៅក្នុងប្រព័ន្ធតុលាការ ដោយអនុម័តច្បាប់ពាក់ព័ន្ធនានានៃកំណែទម្រង់ (សាធារណរដ្ឋកូរ៉េ);

118.91 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកកម្ពស់នីតិរដ្ឋ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន (សឹង្ហបូរី)

118.92 បន្តចាត់វិធានការនានា ដើម្បីពង្រឹងការស៊ើបអង្កេតដោយឯករាជ្យ និងមិនលំអៀង លើករណីរំលោភសិទ្ធិមនុស្ស (អាហ្សង់ទីន);

118.93 ដាក់ឲ្យអនុវត្តនូវប្រព័ន្ធយុត្តិធម៌អនីតិជន ដែលសម្របទៅតាមតម្រូវការរបស់ជនល្មើសជាអនីតិជន ជាពិសេស ដើម្បីធានាថា អនីតិជនមិនត្រូវបានឃុំខ្លួនជាមួយមនុស្សពេញវ័យ (ឌ្យីប៊ូទី);

118.94 អនុម័តវិធានការចាំបាច់នានា ដើម្បីធានាពីការទទួលបានសេវាយុត្តិធម៌សម្រាប់ស្ត្រី (អេស្ប៉ាញ);

118.95 ពង្រឹងមធ្យោបាយនានា តាមការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ និងធ្វើឲ្យប្រព័ន្ធនេះ កាន់តែងាយទទួលបានដល់អ្នកក្រីក្រ (សេណេហ្គាល់);

118.96 ពង្រឹងអាជ្ញាធរអនុវត្តន៍ច្បាប់ (អ៊ីរ៉ាក់);

118.97 ធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀត រួមទាំងផ្នែកហិរញ្ញវត្ថុ ដើម្បីធានាពីការអនុវត្តដោយរលូន និងការបញ្ចប់ដោយជោគជ័យនូវសាលាក្ដីខ្មែរក្រហម ដោយសហការជាមួយសហគមន៍អន្តរជាតិ (ជប៉ុន);

118.98 ជាបញ្ហាបន្ទាន់ ត្រូវធានាថា ថវិកាពីភាគីជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានបំពេញ (ណូវ៉ែលហ្សេឡង់);

118.99 បន្តវិធានការនានាដែលខ្លួនបានចាត់ឡើង លើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គជំនុះជម្រះវិសាមញ្ញ និងបន្តសហការជាមួយអ្នករាយការណ៍ពិសេស (រ៉ូម៉ានី);

118.100 ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ផ្តល់ការការពារដោយប្រសិទ្ធភាពដល់គ្រួសារដែលជាកោសិកាគ្រឹះ និងធម្មជាតិនៃសង្គម(អេហ្ស៊ីប)

118.101 ស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួន ក្រោម UPR កាលពីជុំមុន ធ្វើការឆ្ពោះទៅរកការធានាឲ្យមានការប្រើប្រាស់ដោយសេរីនូវប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក និងធ្វើសេរីភាវូបនីយកម្មនៃវិធានកម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក តាមរយៈការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធអ៊ីនធើណិត ស្របតាមស្តង់ដារអន្តរជាតិ (ហុងគ្រី);

118.102 ធានាថា ទស្សនៈនៃការបរិហារកេរ្តិ៍ និងការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវស្របគ្នានឹងសិទ្ធិមនុស្សក្នុងការទទួលបានសេរីភាពនៃការបញ្ចេញមតិ ទាំងនៅក្នុងច្បាប់ ទាំងនៅក្នុងការអនុវត្តជាក់ស្តែង (អាល្លឺម៉ង់);

118.103 ដោះស្រាយបញ្ហានៃការធ្វើនិយ័តកម្មសេរីភាពនៃការបញ្ចេញមតិ តាមអ៊ីនធើណិត តាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ (ស៊ុយអែត);

118.104 លើកកម្ពស់បរិយាកាសអំណោយផលនិងមានសុវត្ថិភាពមួយដែលអនុញ្ញាតឲ្យបុគ្គល និងក្រុមនានា ប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិ សេរីភាពមានសមាគម និងសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី ហើយត្រូវបញ្ចប់ការយាយី ការបំភិតបំភ័យ ការចាប់ខ្លួនតាមទំនើងចិត្ត និងការវាយប្រហារលើរាងកាយ ជាពិសេស ក្នុងបរិបទនៃការធ្វើបាតុកម្មដោយសន្តិវិធី (ស្វីស);

118.105 *គោរព និងការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដើម្បីអនុវត្តការងាររបស់ពួកគេដោយគ្មានការរារាំង ការបំភិតបំភ័យឬការយាយី(អូទ្រីស)*

118.106 *ធានាសិទ្ធិរបស់បុគ្គល និងអង្គការការពារ និងលើកស្ទួយសិទ្ធិមនុស្ស រួមទាំងការការពារ និងការលើកស្ទួយសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និង សេរីភាពមានសមាគម (កូឡុំប៊ី);*

118.107 *ធានាការការពារកម្មករ ដែលប្រើសិទ្ធិមានសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី និងមានសមាគម និងអនុញ្ញាតឲ្យមានការអនុវត្តដោយពេញលេញ នូវសិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេស (ក្រូអាត);*

118.108 *ការពារយ៉ាងសកម្មដល់សិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំដោយសន្តិវិធី ដោយធានាថា ការរឹតត្បិតណាមួយទៅលើសិទ្ធិទាំងនេះ ត្រូវធ្វើឡើងត្រឹមត្រូវតាមច្បាប់ តាមការចាំបាច់ និងសមាមាត្រ (ណូវែលហ្សេឡង់);*

118.109 *អនុម័ត និងអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការប្រើអំពើហិង្សាទៅលើបាតុករ ស្របតាមច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងអនុញ្ញាតឲ្យក្រុមទាំងអស់ រួមទាំងក្រុមដែលមានទស្សនៈប្រឆាំង មានសិទ្ធិពេញលេញឡើងវិញ នូវសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី និងមានសមាគម (សាធារណរដ្ឋឆែក);*

118.110 *ធានាសេរីភាពនៃការប្រមូលផ្តុំ និងមានសមាគម ហើយត្រូវទទួលស្គាល់សារៈសំខាន់របស់សហជីព និងសង្គមស៊ីវិលផ្សេងៗនៅក្នុងសង្គមប្រជាធិបតេយ្យ (ហូឡង់)*

118.111 *ទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តជាក់ស្តែង ធានាការគោរពដោយពេញលេញនូវសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី និងមានសមាគម ស្របតាមច្បាប់អន្តរជាតិ (អូស្ត្រាលី);*

118.112 *ធានាថា សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សត្រូវបានគោរព ស្របតាមអនុសាសន៍ ដែលបានទទួលយកដោយកម្ពុជា ក្នុងអំឡុងពេល* UPR *ជុំទីមួយ (បែលហ្ស៊ិក);*

118.113 *អនុម័តវិធានការចាំបាច់នានា ដើម្បីគោរព និងការពារអ្នកការពារសិទ្ធិមនុស្ស* (ឈីលី);

118.114 *ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស ជាពិសេស តាមរយៈការផ្តន្ទាទោសជនល្មើសនៃអំពើហិង្សា ឬការបំភិតបំភ័យប្រឆាំងពួកគេ* (បារាំង);

118.115 *ការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស* (អាល្លឺម៉ង់);

118.116 *ធានាថា សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស ដើម្បីបំពេញការងារដោយគ្មានការរារាំង ការបំភិតបំភ័យ ឬការយាយី ត្រូវបានគោរព និងការពារ ដូចដែលបានផ្តល់អនុសាសន៍ និងទទួលយកដោយកម្ពុជា ក្នុង* UPR *កាលពីជុំមុន* (អៀរឡង់ដ៍);

118.117 *ដោះស្រាយពីកង្វះខាត នៅក្នុងការបោះឆ្នោត ដែលបានលើកឡើងដោយតួអង្គជាច្រើន រួមទាំងអ្នករាយការណ៍ពិសេសស្តីពីកម្ពុជា និងបេសកកម្មជំនួយបច្ចេកទេសរបស់សហព័ន្ធអឺរ៉ុប* (ស៊ុយអែត);

118.118 *ត្រឹមដំណាច់ឆ្នាំ២០១៤ អនុម័ត និងអនុវត្តអនុសាសន៍នានាស្តីពីការកែទម្រង់ការបោះឆ្នោត របស់អ្នករាយការណ៍ពិសេសស្តីពីកម្ពុជា* (ចក្រភពអង់គ្លេស);

118.119 *អនុវត្តកំណែទម្រង់ការបោះឆ្នោតសំខាន់ៗដើម្បី៖ (១)កែលំអពីសុចរិតភាពនៃប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត, (២)ធានាថាបេក្ខជនទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និង(៣)ធានាថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឯករាជ្យពេញលេញ* (សហរដ្ឋអាមេរិក);

118.120 *ធានាថា បេក្ខជនទាំងអស់មានសិទ្ធិស្មើគ្នា ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ជៀសវាងការបញ្ឆោតអ្នកបោះឆ្នោត និងជំរុញវប្បធម៌នៃការសន្ទនាគ្នាក្នុងចំណោមគណៈ បក្សនយោបាយទាំងអស់* (សាធារណរដ្ឋឆែក);

118.121 គណបក្សដែលពាក់ព័ន្ធ គួរលើកស្ទួយការសន្ទនា និងសហប្រតិបត្តិការ អំពីលទ្ធផលនៃការបោះឆ្នោតសកលកាលពីឆ្នាំកន្លងទៅ ដើម្បីធ្វើឲ្យស្ថានការណ៍វិលមករកភាពប្រក្រតីវិញដោយឆាប់រហ័ស និងដើម្បីធ្វើឲ្យសម្រេចបាននូវការកែទម្រង់ការបោះឆ្នោត (ជប៉ុន);

118.122 អនុវត្តកំណែទម្រង់ការបោះឆ្នោត តាមអនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីកម្ពុជា ដើម្បីបង្ការពីការកើតឡើងផ្ទួនៗនៃបញ្ហាទាំងនេះ នៅពេលខាងមុខ (ណូវ៉ែលហ្សេឡង់ដ៍);

118.123 អនុវត្តកំណែទម្រង់ការបោះឆ្នោត ដើម្បីធានាពីដំណើរការបោះឆ្នោតដែលអាចជឿទុកចិត្តបាន (អូស្ត្រាលី)

118.124 បង្កើនការប្រយុទ្ធប្រឆាំងនឹងការផ្តល់ការងារក្មេងក្វាយ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយប្រទេសនានា ដែលជួលស្ត្រីកម្ពុជាឲ្យធ្វើការនៅទីនោះ (អេស្ប៉ាញ);

118.125 ពង្រឹងគោលនយោបាយរបស់ខ្លួន ដើម្បីកែលម្អស្តង់ដារការងារសម្រាប់កម្មករទាំងអស់ និងបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយពលកម្មកុមារ (អេស្ប៉ាញ);

118.126 បន្តពង្រឹងកម្មវិធីបង្កើតការងារប្រកបដោយប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងវិសមភាពសង្គម (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា));

118.127 ជំរុញឲ្យមានច្បាប់ស្តីពីការទទួលខុសត្រូវសង្គមរបស់សាជីវកម្ម និងការផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដើម្បីធ្វើឲ្យប្រសើរដល់សុវត្ថិភាពនៅកន្លែងធ្វើការ និងលក្ខខណ្ឌការងារសម្រាប់និយោជិក (ម៉ិកស៊ិកូ);

118.128 ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ជនបទ និងភ្ជាប់គម្លាតទ្រព្យធនរវាងតំបន់ជនបទ និងទីក្រុង (ស្រីលង្កា);

118.129 បញ្ឈប់ការដកហូតដោយបង្ខំ និងធានាដំណើរការប្រកបដោយយុត្តិធម៌ និងតម្លាភាព ទាក់ទងទៅនឹងសិទ្ធិប្រើប្រាស់ដីធ្លី (ម៉ិកស៊ិកូ);

118.130 អនុវត្តក្របខ័ណ្ឌច្បាប់ដ៏តឹងរឹងមួយ ដែលធានាថា ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី ត្រូវធ្វើត្រឹមត្រូវតាមផ្លូវច្បាប់ ចរចា និងត្រូវផ្តល់សំណងដោយយុត្តិធម៌ (អូទ្រីស);

118.131 បន្តកិច្ចខិតខំប្រឹងប្រែងនៅក្នុងបញ្ហាដីធ្លី រួមទាំង តាមរយៈការអនុវត្តប្រកប ដោយប្រសិទ្ធភាព និងតម្លាភាពនូវការបែងចែកដីធ្លី (បារាំង);

118.132 ធានាថា ការផ្តល់ដីសម្បទាន ឬការដកហូតកម្មសិទ្ធិដី ឬសិទ្ធិស្របច្បាប់ ក្នុង ការប្រើប្រាស់ដីធ្លី មិននាំឲ្យមានការរំលោភបំពានសិទ្ធិមនុស្សនោះទេ (អាល្លឺម៉ង់);

118.133 បន្តជំរុញវឌ្ឍនភាពទៅលើបញ្ហាសំខាន់ៗសម្រាប់ការលើកស្ទួយសិទ្ធិមនុស្ស និងប្រជាធិបតេយ្យការូបនីយកម្មរបស់ខ្លួន ជាពិសេស នៅក្នុងកំណែទម្រង់តុលាការ និង វិធានការនានាដើម្បីដោះស្រាយបញ្ហាដីធ្លី (ជប៉ុន);

118.134 បន្តកំណែទម្រង់ប្រព័ន្ធកាន់កាប់ដីធ្លី ដើម្បីឆ្លើយតបនឹងគោលដៅជាតិ នៃ ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការការពារបរិស្ថាន (ម៉ូរ៉ុកកូ);

118.135 បង្កើនវិធានការនានា ដើម្បីដោះស្រាយការបណ្តេញចេញពីដីធ្លីដោយ ខុស ច្បាប់ រួមទាំង វិធានការនានាប្រឆាំងនឹងជនជាតិដើមភាគតិច និងពិចារណាពង្រឹង ក្រប ខ័ណ្ឌច្បាប់ ស្របតាមស្តង់ដារអន្តរជាតិ (អ៊ីតាលី);

118.136 បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីសម្រេចបានគោលដៅជាតិសម្រាប់ ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រួមទាំងតាមរយៈ កំណែទម្រង់ការគ្រប់គ្រងដីធ្លី (ម៉ាឡេស៊ី);

118.137 បន្តចាត់វិធានការការពារសិទ្ធិសង្គម រួមទាំង សិទ្ធិកុមារ ស្ត្រី និងជនពិការ (អ៊ុយបេគីស្ថាន);

118.138 *បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកាត់បន្ថយវិសមភាពប្រាក់ចំណូលរវាងតំបន់ជនបទ និងទីក្រុង ដោយមានការគាំទ្រពីសហគមន៍អន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធដទៃទៀត* (ប៊ូតង់);

118.139 *បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីរក្សាស្ថិរភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើការខិតខំប្រឹងប្រែងល្អៗដើម្បីអភិវឌ្ឍ និងកែលំអជីវភាពរបស់ប្រជាជន* (ចិន);

118.140 *បន្តចាត់វិធានការនានាដើម្បីធានាពីការលុបបំបាត់ភាពក្រីក្រ និងការទទួលបានសេវាសុខភាព និងអប់រំ* (គុយបា);

118.141 *បន្តកាត់បន្ថយអត្រាភាពក្រីក្រនៅតំបន់ជនបទ និងគម្លាតទ្រព្យធនរវាងអ្នកមាន និងអ្នកក្រ និងរវាងប្រជាជននៅជនបទ និងទីក្រុង* (មីយ៉ាន់ម៉ា);

118.142 *កាត់បន្ថយគម្លាតរវាងតំបន់ទីក្រុង និងតំបន់ជនបទ តាមរយៈការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ* (អ៊ីរ៉ាក់);

118.143 *ដោយសហការជាមួយសហគមន៍អន្តរជាតិ អនុវត្តកម្មវិធីនានា ប្រកបដោយប្រសិទ្ធភាព សំដៅកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតំបន់ជនបទនៃប្រទេស* (អាហ៊្សែបៃហ្សង់);

118.144 *បន្តធ្វើការទៅលើការឆ្លើយតបនឹងគោលដៅរបស់ខ្លួននៅក្នុងវិស័យអភិវឌ្ឍន៍ដូចបានដាក់ចេញនៅក្នុងសេចក្តីប្រកាសសហស្សវត្ស* (សហព័ន្ធរុស្ស៊ី);

118.145 *បន្តបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាពីការទទួលបានសិទ្ធិសង្គម សេដ្ឋកិច្ច ដោយប្រជាពលរដ្ឋ* (សហព័ន្ធរុស្ស៊ី);

118.146 *ពង្រឹង និងកែលម្អបណ្តាញសុវត្ថិភាពសង្គម* (អ៊ីរ៉ាក់);

118.147 គាំទ្របន្ថែមទៀតដល់ការអភិវឌ្ឍន៍វិស័យសុខាភិបាល ដោយយកចិត្តទុកដាក់ជាពិសេសដល់តំបន់ជនបទដែលភាពអាចរកបាន ការទទួលបានគុណភាព និងការប្រើប្រាស់សេវាកម្មសុខភាព នៅតែមានមានកំរិត ក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋរបស់ខ្លួនបន្ថែមទៀត (រដ្ឋប៉ាឡេស្ទីន);

118.148 បង្កើនកិច្ចខិតខំប្រឹងប្រែងជាបន្តសំដៅលើកកម្ពស់សិទ្ធិទទួលបានសុខភាពប្រកបដោយសមធម៌ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប (ទីម័រខាងកើត);

118.149 អភិវឌ្ឍកម្មវិធីជាតិបន្ថែមទៀត ដោយផ្តោតលើការផ្តល់សេវាសុខភាពដល់ប្រជាជន ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ (ទីម័រខាងកើត);

118.150 ផ្តល់ការព្យាបាលដោយឥតគិតថ្លៃ ដល់ស្ត្រី និងបុរស ដែលរស់នៅជាមួយមេរោគអេដស៍ / ជំងឺអេដស៍ ដើម្បីបង្ការការចម្លងពីម្តាយទៅកូន (អ៊ុយរុយហ្គាយ);

118.151 បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមទាំង មធ្យោបាយការពារកំណើតទំនើប ជាពិសេស សម្រាប់ស្ត្រីដែលរស់នៅតំបន់ជនបទ (អ៊ុយរុយហ្គាយ);

118.152 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស ជាពិសេស នៅក្នុងវិស័យសុខាភិបាលនៃប្រជាជនរបស់ខ្លួន (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា));

118.153 បន្តអនុម័តគោលនយោបាយសង្គមប្រកបដោយប្រសិទ្ធភាពស្តីពីការទទួលបានសេវាអប់រំ និងសុខភាព ជាពិសេស សម្រាប់ស្ត្រី និងកុមារ (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា));

118.154 បន្តកែលម្អគុណភាពសេវាសុខភាពរបស់ខ្លួន តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិរបស់ខ្លួន (ប្រុយណេដារូសាឡាម);

118.155 បន្តយកចិត្តទុកដាក់ដល់សិទ្ធិទទួលបានសុខភាពរបស់កុមារ មនុស្សចាស់ ក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះដទៃទៀត (ចិន);

118.156 បន្តលើកកម្ពស់ការអភិវឌ្ឍវិស័យសុខាភិបាល ប្រកបដោយចីរភាព ដោយផ្តល់អាទិភាពដល់ភាពជាដៃគូជាមួយសហគមន៍ជាតិ ក្នុងការផ្តល់សេវាសុខភាពដល់ប្រជាពលរដ្ឋគ្រប់រូប (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ);

118.157 មិនត្រឹមតែបន្ត ថែមទាំងពង្រឹងគោលនយោបាយ និងកម្មវិធីនានាដែលជួយសម្រួលដល់ការទទួលបានសេវាថែទាំសុខភាពសម្រាប់ជនងាយរងគ្រោះ (សេនេហ្គាល់)

118.158 ជំរុញសកម្មភាព និងយុទ្ធសាស្ត្រនានាសំដៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សទាំងអស់ ជាពិសេស គោលដៅទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិទទួលបានការអប់រំ និងការថែទាំសុខភាព និងសិទ្ធិរបស់ក្រុមងាយរងគ្រោះ (វៀតណាម);

118.159 បង្កើនការចំណាយថវិកាជាតិរបស់ខ្លួនបន្ថែមទៀតលើវិស័យសុខភាព និងអប់រំ ដើម្បីបំពេញបានតាមទិសដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស (អាហ្វ៊ែរបៃហ្សង់)

118.160 លើកកម្ពស់ការទទួលបានការអប់រំ និងសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ជាពិសេស នៅតាមតំបន់ជនបទ រួមទាំងតាមរយៈកិច្ចសហការដែលត្រូវបង្កើនឡើងជាមួយប្រទេសជិតខាង និងដៃគូអភិវឌ្ឍន៍ (ថៃ);

118.161 ធានាថា ការអប់រំជាមូលដ្ឋានគឺជាកាតព្វកិច្ច និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហានៃអត្រាបោះបង់ការសិក្សាដ៏ខ្ពស់នៅតាមសាលា និងក្នុងការលើកស្ទួយសិទ្ធិក្មេងស្រីឲ្យទទួលបានការអប់រំ (ស្លូវេនី)[៩]

118.162 បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបានការអប់រំបឋមជាសកល ស្របតាមចក្ខុវិស័យនៃផែនការជាតិស្តីពី "ការអប់រំសម្រាប់ទាំងអស់គ្នា" (ស្រីលង្កា);

---

៩. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នេះ។

118.163 បន្តអនុវត្តវិធានការនានាសំដៅកែលំអដល់វិជ្ជមាត្រ និងគុណភាពនៃសេវាអប់រំ ជាពិសេស នៅតាមតំបន់ជនបទដាច់ស្រយាល (រដ្ឋប៉ាឡេស្ទីន);

118.164 ដោយសហការជាមួយ UNDP និង UNESCO បន្តកែលម្អប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ប្រជាពលរដ្ឋរបស់ខ្លួន (ស៊ីង្ហបូរី);

118.165 បន្តជំរុញការចុះឈ្មោះចូលរៀនដោយឥតគិតថ្លៃ (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ);

118.166 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រែក្លាយវឌ្ឍនភាពរបស់ខ្លួន នៅកំរិតត្រឹមសូចនាករម៉ាក្រូសេដ្ឋកិច្ច ទៅជាវិធានការកាន់តែរឹងមាំនៃយុត្តិធម៌សង្គម និងឈានដល់កំរិតខ្ពស់នៃការអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេស ដោយធានាពីការអប់រំមូលដ្ឋានជាសកល ជាកាតព្វកិច្ច និងដោយឥតគិតថ្លៃ (អេហ្ស៊ីប);

118.167 បន្តធ្វើការលើផែនការជាតិរបស់ខ្លួន ស្តីពី "ការអប់រំសម្រាប់ទាំងអស់គ្នា" ដើម្បីឲ្យកុមារ និងយុវជនកម្ពុជាទាំងអស់ ទទួលបានបន្ថែមទៀតនូវសេវាអប់រំប្រកបដោយសមធម៌ (មីយ៉ាន់ម៉ា);

118.168 បន្តលើកកម្ពស់កម្មវិធី ដើម្បីទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេស នៅក្នុងការអប់រំបឋមសិក្សា (នីការ៉ាហ្គ័រ);

118.169 បន្តការពារ និងលើកស្ទួយសិទ្ធិជនពិការ (ឌ្យីប៊ូទី)

118.170 បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិជនពិការ (អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម));

118.171 បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនលើសុខភាព ប្រព័ន្ធសេវាសង្គម និងការអប់រំ ដើម្បីជួយជនដែលងាយរងគ្រោះ និងជនពិការ ជាពិសេស ស្ត្រី និងកុមារ (អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម));

119. *អនុសាសន៍ទាំងឡាយខាងក្រោមនេះ នឹងត្រូវពិនិត្យពិច័យដោយកម្ពុជា ថានឹងផ្តល់ចំលើយឲ្យបានទាន់ពេល មិនឲ្យហួសពីសម័យប្រជុំលើកទី២៦ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលនឹងត្រូវប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០១៤៖*[១០]

119.1 *ធ្វើការប្រកាសជាចាំបាច់ តាមមាត្រា៤១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (*អូទ្រីស*);

119.2 *ធ្វើការប្រកាសជាចាំបាច់ តាមមាត្រា២១ និងមាត្រា២២ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬទណ្ឌកម្មដទៃទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក* (*អូទ្រីស*);

119.3 *ពិចារណាពីការចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (*ក្រូអាត*);

119.4 *ចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (*ស្លូវ៉ាគី*);

119.5 *ចុះហត្ថលេខា និងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (*បារាំង*);

119.6 *បញ្ចប់ឲ្យបានរហ័សនូវដំណើរការនៃការតម្រង់ច្បាប់ជាតិរបស់ខ្លួន ឲ្យស្រប តាមបទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (*ទុយនេស៊ី*);

119.7 *ចាត់វិធានការសមស្របនានា ដើម្បីតម្រង់ច្បាប់ជាតិឲ្យស្របយ៉ាងពេញលេញ តាមកាតព្វកិច្ចទាំងអស់ ក្រោមលក្ខន្តិកៈទីក្រុងរ៉ូម រួមទាំង តាមរយៈការអនុម័តបទប្បញ្ញត្តិជាក់លាក់នានា សំដៅសហការយ៉ាងល្អិតល្អន់ និងយ៉ាងឆាប់រហ័សជាមួយតុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (*ក្រូអាត*);

---

១០. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ក្នុងសម័យប្រជុំលើកទី២៦របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រាជរដ្ឋាភិបាលកម្ពុជាបានសំរេចធ្វើការកត់សំគាល់លើអនុសាសន៍នានា ដូចមានជាបន្តបន្ទាប់ខាងក្រោមវក្យខ័ណ្ឌនេះ។

119.8 ពិនិត្យឡើងវិញលើច្បាប់ជាតិរបស់ខ្លួន ដោយអនុម័តបទប្បញ្ញត្តិជាក់លាក់នានា ដើម្បីសហការយ៉ាងពេញលេញ និងភ្លាមៗ ជាមួយតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ឡាតវី)

119.9 បង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យមួយ ដែលមានអាណត្តិចាំបាច់ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក (ដាណឺម៉ាក);

119.10 តែងតាំងយន្តការបង្ការថ្នាក់ជាតិ ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម (ព័រទុយហ្គាល់);

119.11 កសាងលើរចនាសម្ព័ន្ធដែលមានស្រាប់ និងបង្កើតយន្តការបង្ការថ្នាក់ជាតិមួយស្របតាមស្តង់ដារពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម(ស៊ែបប៊ី)

119.12 បង្កើតឲ្យបានរហ័សនូវយន្តការបង្ការថ្នាក់ជាតិប្រឆាំងទារុណកម្ម (ទុយនេស៊ី)

119.13 ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់អ្នកកាន់អាណត្តិនីតិវិធីពិសេសនានា នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (ទុយនេស៊ី);

119.14 ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់អ្នកកាន់អាណត្តិនីតិវិធីពិសេសនៃអង្គការសហប្រជាជាតិ (ប្រារាំង);

119.15 ដាក់ការអញ្ជើញជាអចិន្ត្រៃយ៍មួយដល់នីតិវិធីពិសេសតាមប្រធានបទទាំងអស់ (ម៉ុងតេណេហ្គ្រូ);

119.16 ពង្រឹងកិច្ចសហការរបស់ខ្លួន ជាមួយអ្នកកាន់អាណត្តិនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស តាមរយៈការឆ្លើយតបជាវិជ្ជមាន ទៅនឹងសំណើសុំទស្សនកិច្ចដែលមិនទាន់បានសម្រេច និងពិចារណាជាយថាហេតុពីការដាក់ការអញ្ជើញជាអចិន្ត្រៃយ៍មួយ ទៅគ្រប់អ្នកកាន់អាណត្តិនីតិវិធីពិសេស (ឡាតវី);

119.17 ពង្រឹងកិច្ចសហការរបស់ខ្លួនបន្ថែមទៀតជាមួយអ្នករាយការណ៍ពិសេសស្តីពីកម្ពុជា និងពិចារណាអញ្ជើញអ្នកកាន់អាណត្តិតាមប្រធានបទនៃនីតិវិធីពិសេស ដើម្បីទទួលបានអត្ថប្រយោជន៍ពីជំនាញបច្ចេកទេសរបស់ពួកគេ (ប៉ូឡូញ);

119.18 ពិគ្រោះយោបល់ជាប្រព័ន្ធជាមួយសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលស្តីពីការអនុវត្តUPR អនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញានៃអង្គការសហប្រជាជាតិ និងអនុសាសន៍របស់នីតិវិធីពិសេសនៃអង្គការសហប្រជាជាតិ (អូទ្រីស);

119.19 ស្វែងរកជំនួយបច្ចេកទេស ពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងពីអ្នករាយការណ៍ពិសេស អំពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពនៃការបញ្ចេញទស្សនៈ និងមតិ តាមមធ្យោបាយណាដែលអាចធ្វើបាន ដើម្បីកែតម្រូវច្បាប់ស្តីពីសារព័ត៌មាន (ប្រេស៊ីល);

119.20 ចាត់វិធានការនានា ដើម្បីពង្រឹងឯករាជ្យភាព និងការប្រព្រឹត្តិទៅនៃតុលាការរបស់ប្រទេស ជាពិសេស កាត់បន្ថយឲ្យបានច្រើននូវពេលវេលាដែលចំណាយដោយបុគ្គលជាប់ឃុំបណ្តោះអាសន្ន (អូទ្រីស);

119.21 ស៊ើបអង្កេតដោយមិនលំអៀង ទៅលើករណីនៃការប្រើកម្លាំងហួសហេតុប្រឆាំងនឹងអ្នកតវ៉ា និងករណីនៃការសម្លាប់មនុស្ស ក្នុងអំឡុងពេលធ្វើបាតុកម្មនាពេលថ្មីៗនេះ (សាធារណរដ្ឋឆែក);

119.22 ពិនិត្យឡើងវិញលើករណីច្បាប់ទាំងអស់ប្រឆាំងនឹងបុគ្គលដែលត្រូវបានឃុំខ្លួន តាមការស៊ើបអង្កេតព្រហ្មទណ្ឌ ឬតុលាការ ដោយសារតែការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ដាណឺម៉ាក);

119.23 ធានាបរិយាកាសមួយ ដែលអំណោយផលដល់សកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងតួអង្គសង្គមស៊ីវិលដទៃទៀត (ទុយនេស៊ី);

119.24 ការពារសមាជិកគណបក្សប្រឆាំង អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ពីការយាយី និងការចាប់ខ្លួនតាមទំនើងចិត្ត ព្រមទាំងលុបចោលការរឹតត្បិតទាំងអស់លើបាតុកម្មដោយសន្តិវិធី (ព័រទុយហ្គាល់);

119.25 ធានាឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ ពីឥទ្ធិពលនយោបាយ និងធ្វើសេរីភាវូបនីយកម្មវិធានកម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ (សាធារណរដ្ឋឆែក);

119.26 បង្កើតផែនការសកម្មភាពមួយ ដោយធានាថា ច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធើណិត ស្របតាមការប្តេជ្ញាចិត្តរបស់កម្ពុជាដើម្បីធានាការពារសេរីភាពនៃការបញ្ចេញមតិ និងព័ត៌មានក្នុងគោលបំណងធានាការទទួលបានដោយសេរីនូវប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ធ្វើសេរីភាវូបនីយកម្មវិធានកម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក និងអនុញ្ញាតឲ្យអ្នកបង្កើតប្លក់សរសេរអ៊ីនធើណិត អ្នកសារព័ត៌មាន អ្នកប្រើអ៊ីនធើណិតដទៃទៀត និងអង្គការក្រៅរដ្ឋាភិបាល ដើរតួនាទីពេញលេញ និងសកម្ម ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស (ហូឡង់ដ៍);

119.27 លុបចោល ឬធ្វើវិសោធនកម្មមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ដូចជាមាត្រាទាំងឡាយទាក់ទងនឹងការបរិហារកេរ្តិ៍ ឬការប្រមាថសេចក្តីសំរេចរបស់តុលាការជាដើមដែលនឹងធ្វើឲ្យច្បាប់ក្នុងស្រុករបស់កម្ពុជាមានលក្ខណៈស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនស្តីពីសេរីភាពនៃការបញ្ចេញមតិ (សហរដ្ឋអាមេរិក)

119.28 ធ្វើការស៊ើបអង្កេតទៅលើអង្គហេតុនៃឧប្បត្តិហេតុនាពេលថ្មីៗនេះ និងទប់ស្កាត់មិនឲ្យមាននិទណ្ឌភាព ចំពោះការរំលោភបំពាន ដែលត្រូវបានប្រព្រឹត្ត (អេស្ប៉ាញ)

119.29 ធានាការពារដល់ការប្រើប្រាស់ដោយប្រសិទ្ធភាពនូវសិទ្ធិមនុស្ស ក្នុងការប្រមូលផ្តុំ ជាពិសេសទាក់ទងនឹងការគ្រប់គ្រងហ្វូងមនុស្ស បង្កើតសេចក្តីណែនាំច្បាស់លាស់ ស្របតាមស្តង់ដារសិទ្ធិមនុស្ស សម្រាប់ការប្រើប្រាស់អាវុធ ផ្តល់ការ

*បណ្តុះបណ្តាលដល់នគរបាល អំពីការប្រព្រឹត្តិ (សីលធម៌) របស់ខ្លួន ដែលត្រូវស្រប តាមសិទ្ធិមនុស្ស ហាមឃាត់ការប្រើអំពើហិង្សាដោយកម្លាំងសន្តិសុខក្រៅផ្លូវការ ឬ ដែលស្លៀកពាក់ស៊ីវិល និងធានាដល់ជនទាំងអស់ដែលត្រូវបានឃុំខ្លួន មានសិទ្ធិជួប គ្រួសារ និងមេធាវីរបស់ខ្លួន បានទាន់ពេល (អាល្លឺម៉ង់);*

119.30 *បន្តអនុវត្តសារាចរណែនាំ ឆ្នាំ២០១២ ស្តីពី ការផ្តល់សម្បទានដីធ្លី (អេស្ប៉ាញ)*

119.31 *ស្របនឹងការងារកំពុងបន្តរបស់ខ្លួន អំពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវ ធ្វើការពិនិត្យឡើងវិញជាបន្ទាន់ពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច មុនពេលការផ្អាក បច្ចុប្បន្ន អំពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានលុបចោល (ចក្រភពអង់គ្លេស);*

119.32 *ចាត់វិធានការនានាដើម្បីអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការ ដោយមានការចូលរួមប្រកបដោយអត្ថន័យពីសង្គមស៊ីវិល ដើម្បីផ្តល់អាទិភាពដល់ ការដោះស្រាយវិវាទដីធ្លី ដោយគោរពយ៉ាងពេញលេញតាមនីតិរដ្ឋ(សហរដ្ឋអាមេរិក)*

119.33 *បង្កើតនិងអនុវត្តយុទ្ធសាស្ត្រជំនួសនានាដើម្បី ជួយដល់អ្នកទាំងឡាយ ណាដែលត្រូវបានផ្លាស់ប្តូរទីលំនៅ ដោយសារតែការរឹបអូសដី និងធានាថា បុគ្គល ទាំងនោះ មានលំនៅស្ថានសមរម្យ និងទទួលបានសេវាជាមូលដ្ឋាន ការថែទាំសុខ ភាព និងការងារជាដើម (សាធារណរដ្ឋកូរ៉េ);*

119.34 *ធ្វើឲ្យការអប់រំទៅជាកាតព្វកិច្ច តាមច្បាប់ និងចាត់វិធានការចាំបាច់ នានា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើ ពុករលួយនៅក្នុងប្រព័ន្ធអប់រំ (ហុងគ្រី);*

120. សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍ទាំងអស់ដែលមាននៅក្នុងរបាយការណ៍នេះ ឆ្លុះ បញ្ចាំងពីគោលជំហរ របស់រដ្ឋដែលដាក់របាយការណ៍ និង/ឬរដ្ឋដែលស្ថិតក្រោមការពិនិត្យឡើងវិ ញ។ សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍ទាំងនេះ មិនគួរត្រូវបានបកស្រាយថាត្រូវបានអនុម័តដោយ ក្រុមការងារទាំងមូលនោះឡើយ។

## ឧបសម្ព័ន្ធ

### *សមាសភាពនៃគណៈប្រតិភូ*

គណៈប្រតិភូកម្ពុជាត្រូវបានដឹកនាំដោយ ឯ.ឧ ម៉ក់ សម្បត្តិ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងមានសមាជិកចូលរួមដូចខាងក្រោម៖

ឯ.ឧ. ញ៉ែម ថ្កាវី សមាជិកសភា ប្រធានគណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង ស៊ើបអង្កេត និងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា

ឯ.ឧ.អ៊ុក វ៉ាណ្ណារិទ្ធ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

ឯ.ឧ. ប៉ុល លឹម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ឯ.ឧ. អ៊ិត រ៉ាឌី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌

ឯ.ឧ. នៃ សំអុល ឯកអគ្គរាជទូតតំណាងអចិន្ត្រៃយ៍កម្ពុជានៅហ្សឺណែវ

លោក សុក ពិសី ជំនួយការ

លោក កែ សុវណ្ណ តំណាងអចិន្ត្រៃយ៍រងកម្ពុជានៅហ្សឺណែវ

លោក អ៊ីវ ហៀង ទីប្រឹក្សារដ្ឋមន្ត្រី

លោក ថៃ ប៊ុនថន ទីប្រឹក្សា

លោក អៀម គន្ធឌី ទីប្រឹក្សា

លោក សុទ្ធ វណ្ណា លេខាទីមួយ

លោកស្រី ឈឿង សូលីដា លេខាទីមួយ

លោក ទូច ខេមរិន ប្រធានការិយាល័យកិច្ចការអន្តរជាតិ អង្គភាពប្រឆាំងអំពើពុករលួយ